# សង្កេតការណ៍ ៦

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

# ការសួរដេញដេញដោល និងពិនិត្យ ភស្តុតាងក្នុងសំណុំរឿង០០២

ខែកក្កដា ឆ្នាំ២០១២




## មាតិកា

ការសួរដេញដោល និងពិនិត្យ
ភស្តុតាងក្នុងសំណុំរឿង០០២
ប្រវត្តិបក្សកុម្មុយនីស្ត ២
ប្រវត្តិសាវតាររបស់ជនជាប់ចោទ ៣
ការសួរដេញដោលជនជាប់ចោទ ៥
ការសួរដេញដោលដើមបណ្តឹង
រដ្ឋប្បវេណី ១៦
ការសួរដេញដោលសាក្សី ១៨
តុលាការបដិសេធការដោះលែង អៀង ធីរិទ្ធ

ក្រុមសង្កេតការណ៍ :
ឆាយ ឈុនលី, ឌី សុជាតា,
លឹម ជ័យទត្ត និង ចាន ប្រាថ្នា



នួន ជា ក្នុងបន្ទប់សវនាការ ខែធ្នូ ឆ្នាំ២០១១ (រូបថត៖ អ.វ.ត.ក)

# សវនាការស្តីពីការសួរដេញដោល និងពិនិត្យភស្តុតាងក្នុងសំណុំរឿង០០២ ថ្ងៃទី៥-១៥ ខែធ្នូ ឆ្នាំ២០១១

*ដោយ ឈុនលី, ឌី សុជាតា, ចាន់ ប្រាថ្នា និង លឹម ជ័យទត្ត*

## សេចក្តីផ្តើម

*នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តើមបើកសវនាការសួរដេញដោល និងពិនិត្យលើភស្តុតាង បន្ទាប់ពីមានសវនាការនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងលើអង្គសេចក្តីនៃសំណុំរឿង០០២ ដែលបានប្រព្រឹត្តធ្វើឡើងកាលពីថ្ងៃទី២១ដល់២៣ ខែវិច្ឆកា ឆ្នាំ២០១១ កន្លងមក ។ សវនាការនេះ បានចាប់ផ្តើមជាមួយនឹងការសួរដេញដោលជនជាប់ចោទទាក់ទងនឹងប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា រួមទាំងប្រវត្តិសាវតាររបស់ជនជាប់ចោទ នួន ជា, អៀង សារី, និង ខៀវ សំផន តាមដីកាដំណោះស្រាយ ។ ភាគីទាំងអស់ត្រូវបានអង្គជំនុំជម្រះកម្រិតឲ្យសួរត្រឹមតែអង្គហេតុដែលពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងសាវតាររបស់ជនជាប់ចោទម្នាក់ៗតែប៉ុណ្ណោះ ហើយអង្គហេតុនេះត្រូវបានអានជូនគូភាគី និងសាធារណជនឲ្យបានដឹងជាមុនដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ។*

*ជាដំបូង ចៅក្រមបានធ្វើការសួរដេញដោលជនជាប់ចោទ នួន ជា បន្ទាប់មកជនជាប់ចោទ អៀង សារី ហើយចុងក្រោយគឺជនជាប់ចោទ ខៀវ សំផន ។ ជនជាប់ចោទ អៀង សារី បានប្រើប្រាស់សិទ្ធិក្នុងការមិនធ្វើសក្ខីកម្ម និងឆ្លើយតបនឹងសំណួរទាំងឡាយរបស់ភាគី រួមទាំងចៅក្រមផង ។ រីឯជនជាប់ចោទ ខៀវ សំផន បានអះអាងថា ខ្លួននឹងមិនឆ្លើយតបនឹងសំណួរទាំងឡាយរបស់ភាគីនៅក្នុងសវនាការដែលចោទសួរមកលើខ្លួនឡើយ លុះត្រាតែសហព្រះរាជអាជ្ញាបានបង្ហាញភស្តុតាងដែលចោទប្រកាន់មកលើខ្លួនជាមុនសិន ។ ថ្វីដ្បិតតែ ជនជាប់ចោទ ខៀវ សំផន បានបដិសេធមិនឆ្លើយនឹងសំណួររបស់ភាគីក៏ដោយនៅក្នុងអំឡុងពេលនៃសវនាការ ជនជាប់ចោទរូបនេះបានស្នើសុំអង្គជំនុំជម្រះអានសេចក្តីថ្លែងការណ៍របស់ខ្លួនដើម្បីឆ្លើយតបនឹងចំណុចទាំងឡាយនៃអង្គហេតុដែលទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងប្រវត្តិសាវតាររបស់ខ្លួន ។ ក្នុងចំណោមជនជាប់ចោទទាំងបីរូប មានតែជនជាប់ចោទ នួន ជា ម្នាក់គត់ ដែលយល់ព្រមឆ្លើយនឹងសំណួររបស់ចៅក្រម និងសហព្រះរាជអាជ្ញាដែលចោទសួរមកលើខ្លួន ។*

*នៅក្នុងសវនាការស្តីពីការសួរដេញដោល និងពិនិត្យលើភស្តុតាងនេះ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប និងសាក្សីមួយរូបត្រូវបានកោះហៅមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ សាក្សីរូបនោះត្រូវបានអង្គជំនុំជម្រះចាត់ទុកថាជាសាក្សីសំខាន់ដែលអាចអនុញ្ញាតឲ្យភាគីទាំងអស់សួរដេញដោលពីអង្គហេតុទាំងមូលនៃសម័យកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារមូលហេតុសុខភាព និងវ័យចាស់ជរា សាក្សីរូបនេះមិនអាចចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការឡើយ ហើយការសួរដេញដោលត្រូវធ្វើឡើងតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបន្ទាយមានជ័យដែលជាទីកន្លែងស្នាក់នៅរបស់សាក្សីរូបនេះ ។*

*សវនាការស្តីពីការសួរដេញដោល និងពិនិត្យលើភស្តុតាងដែលរៀបចំឡើងដោយអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះមិនទាន់បញ្ចប់នៅឡើយទេ សវនាការនេះនឹងត្រូវបន្តប្រព្រឹត្តធ្វើនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ បន្ទបន្ទាប់ទៀត ។*

## ១) អង្គហេតុស្តីពីប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា និងប្រវត្តិសាវតាររបស់ជនជាប់ចោទម្នាក់ៗ

*សវនាការសួរដេញដោល និងពិនិត្យលើភស្តុតាងបានចាប់ផ្តើមដោយអានអង្គហេតុរបស់ក្រឡាបញ្ជីពីរនាក់នៃអង្គជំនុំ*

ជម្រះសាលាដំបូងទាក់ទងទៅនឹងប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា និងប្រវត្តិសាវតាររបស់ជនជាប់ចោទ នួន ជា អៀង សារី និងខៀវ សំផន តាមដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ មុនពេលអង្គជំនុំជម្រះអនុញ្ញាតឲ្យមានការសួរដេញដោលជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញអំពីអង្គហេតុដែលរៀបរាប់ខាងលើ ។

## ក) ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ របស់សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ក្រោយពីបក្សកុម្មុយនីស្តឥណ្ឌូចិនបានរលាយនៅក្នុងឆ្នាំ១៩៥១ អតីតសមាជិករបស់បក្សនេះបានបង្កើតអង្គការបដិវត្តន៍ដាច់ដោយឡែកពីគ្នានៅក្នុងប្រទេសនីមួយៗ ហើយបក្សថ្មីមួយដែលបង្កើតឡើងនៅកម្ពុជាមានឈ្មោះថា "បក្សប្រជាជនបដិវត្តន៍ខ្មែរ" ។ បក្សនេះមានការចូលរួមពីក្រុមឥស្សរៈដើម្បីទាមទារឯករាជ្យពីអាណានិគមបារាំង ដែលការទាមទារនេះបានទទួលជោគជ័យ និងត្រូវបានទទួលស្គាល់នៅសន្និសីទទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៤ ។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែរបានធ្វើមហាសមាជ ហើយបានប្តូរឈ្មោះទៅជា "បក្សពលករខ្មែរ" ដែលនេះជាចំណុចចាប់ផ្តើមពិតប្រាកដនៃការបង្កើតចលនាកុម្មុយនីស្តខ្មែរ ។ បក្សនេះបានបង្កើត "មាគ៌ាយុទ្ធសាស្ត្រ" និង "មាគ៌ាយុទ្ធវិធី" ច្បាស់លាស់ ក្នុងឆ្នាំ១៩៦០នៅអំឡុងពេលមហាសន្និបាតបក្សលើកទី១ ។ នៅខែមករា ឆ្នាំ១៩៦៥ "បក្សពលករខ្មែរ" បានអនុម័តសេចក្តីសម្រេចមួយដែលបានបដិសេធចំពោះ "ការផ្លាស់ប្តូរដោយសន្តិវិធី" ទៅកាន់លទ្ធិសង្គមនិយម និងបានបញ្ជាក់ថា "ជាការចាំបាច់ដែលត្រូវប្រើប្រាស់ហិង្សាបដិវត្តន៍" ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិ ។ នៅខែកញ្ញា ឬតុលា ឆ្នាំ១៩៦៦ បក្សពលករខ្មែរត្រូវបានប្តូរឈ្មោះទៅជា "បក្សកុម្មុយនីស្តកម្ពុជា" ដែលបានសម្រេចដោយប្រធានបក្សនៅក្នុងអង្គប្រជុំគណៈមជ្ឈិម ។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ កងកម្លាំងរបស់បក្សកុម្មុយនិស្តកម្ពុជាបានបើកការវាយប្រហារលើកងទ័ពរបស់រដ្ឋាភិបាលនៅភូមិបាយដំរាំ (ភាគខាងត្បូងក្រុងបាត់ដំបង) ហើយរឹបអូសបានអាវុធមួយចំនួន ។ កាលបរិច្ឆេទនៃការវាយប្រហារនេះត្រូវបានបក្សកុម្មុយនិស្តកម្ពុជាកំណត់ថាជាថ្ងៃកំណើតរបស់កងទ័ពបដិវត្តកម្ពុជា ហើយប៉ុន្មានខែក្រោយមក កងកម្លាំងរបស់បក្សកុម្មុយនិស្តកម្ពុជាបានបន្តការវាយប្រហាររបស់ខ្លួននៅទូទាំងប្រទេស ។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេច សីហនុ បានប្រកាសបង្កើត "រណសិរ្សរួបរួមជាតិ" ដើម្បីធ្វើការបះបោរប្រឆាំងរដ្ឋាភិបាល ដែលការប្រកាសនេះធ្វើឡើងក្រោយពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ ជាឱកាសល្អ បក្សកុម្មុយនិស្តកម្ពុជាបានចងសម្ពន្ធ័ភាពជាមួយសម្តេច សីហនុ ហើយបង្កើតរដ្ឋាភិបាលនិរទេសថ្មីមួយមានមូលដ្ឋាននៅទីក្រុងប៉េកាំងមានឈ្មោះថា "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា" និងប្រកាសជាផ្លូវការថ្ងៃទី៥ ខែ



សិស្សានុសិស្សកំពុងតម្រង់ជួរចូលបន្ទប់សវនាការ



ព្រះសង្ឃកំពុងដើរចូលបន្ទប់សវនាការ

ឧសភា ឆ្នាំ១៩៧០ ។ បក្សកុម្មុយនីស្តបានបើកការវាយលុកលើតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាលរបស់ លន់ នល់ ជាបន្តបន្ទាប់ ហើយនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានរំដោះយកទីក្រុងភ្នំពេញ ។ តែទោះបីជាយ៉ាងណាក្តី អត្ថិភាពរបស់បក្សកុម្មុយនិស្តកម្ពុជាត្រូវបានប្រកាសជាផ្លូវការនៅខែកញ្ញា ឆ្នាំ១៩៧៧ ។

## ២) ប្រវត្តិសាវតាររបស់ជនជាប់ចោទម្នាក់ៗ

បន្ទាប់ពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ក្រឡាបញ្ជីបានបន្តអានអំពីតួនាទី និងការចូលរួមក្នុងចលនាកុម្មុយនិស្តរបស់ជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន មុនពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលផ្តោតសំខាន់ទៅលើតួនាទីរបស់ជនជាប់ចោទម្នាក់ៗចាប់តាំងពីការចូលប្រឡូកនយោបាយ រហូតដល់ការចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងខែមេសា ឆ្នាំ១៩៧៥ ។

### ១) ប្រវត្តិសាវតាររបស់ជនជាប់ចោទ នួន ជា

ជនជាប់ចោទ នួន ជា បានចាប់ផ្តើមចូលប្រឡូកយ៉ាងសកម្មក្នុងសកម្មភាពនយោបាយនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ នៅខណៈពេលដែលខ្លួននៅក្នុងប្រទេសថៃ ។ ជនជាប់ចោទរូបនេះបានចូលរួមជាមួយ“អង្គការយុវជនប្រជាធិបតេយ្យ” ដែលស្ថិតនៅក្រោមបក្សកុម្មុយនីស្តថៃ ។ បន្ទាប់មក ជននេះបានវិលមកកម្ពុជាដើម្បីចូលរួមចលនាតស៊ូរបស់បក្សកុម្មុយនិស្តឥណ្ឌូចិននៅ





នាយទាហានកំពុងតម្រង់ជួរចូលបន្ទប់សវនាការ





មន្ត្រីកិច្ចការសាធារណៈចែកសៀវភៅណែនាំរបស់សាលាក្តីជូនប្រជាជន

ដិបន់សំឡូត ដោយទទួលបន្ទុកខាងឃោសនានៅក្នុងបក្ស ។ នៅក្នុងខណៈពេលនោះជនជាប់ចោទ នួន ជា បានទាក់ទងយ៉ាងសកម្មជាមួយក្រុមកុម្មុយនីស្តវៀតណាម និងសមាសភាពកុម្មុយនីស្តនៃចលនាខ្មែរឥស្សរៈ ។ ជនជាប់ចោទរូបនេះបានទៅសិក្សាវគ្គនយោបាយនៅប្រទេសវៀតណាមអស់រយៈពេល២ឆ្នាំ ក្រោយមកក៏ក្លាយទៅជាមេដឹកនាំម្នាក់នៃចលនាកុម្មុយនិស្តសម្ងាត់នៅទីក្រុងភ្នំពេញ ។ ជនជាប់ចោទ នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្សនៅខែកញ្ញា ឆ្នាំ១៩៦០ ហើយចន្លោះឆ្នាំ១៩៧០ និង១៩៧៥ ជនជាប់ចោទរូបនេះមានតួនាទីជាអនុបញ្ញាការយោធាជាន់ខ្ពស់ កងទ័ពប្រជាជននៃចលនារំដោះជាតិកម្ពុជា និងជាប្រធានផ្នែកនយោបាយរបស់កងទ័ពបដិវត្តន៍ ។

## ២) ប្រវត្តិសាវតាររបស់ជនជាប់ចោទ អៀង សារី

គណៈអចិន្ត្រៃយ៍ បន្ទាប់មកទៀតនៅឆ្នាំ១៩៦៣ ត្រូវបានបក្សជ្រើសរើសជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ហើយនៅឆ្នាំ១៩៦៦ ជននេះមានតួនាទីជាលេខាភូមិភាគឦសាន ។ នៅក្នុងឆ្នាំ១៩៧០ ជនជាប់ចោទ អៀង សារី បានធ្វើដំណើរទៅទីក្រុងហាណូយ និងទីក្រុងប៉េកាំងដើម្បីចងសម្ព័ន្ធភាពជាមួយបក្សកុម្មុយនិស្តចិន ។ នៅខែធ្នូ ឆ្នាំ១៩៧០ ជនជាប់ចោទរូបនេះបានរៀបចំឡើងវិញនូវ "វិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា" ដែលមានមូលដ្ឋាននៅទីក្រុងហាណូយ ហើយដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយជនជាប់ចោទ អៀង ធីរិទ្ធ ។ នៅឆ្នាំ១៩៧១ ជនជាប់ចោទ អៀង សារី បានតាំងមូលដ្ឋានជាអចិន្ត្រៃយ៍នៅទីក្រុងប៉េកាំងក្នុងឋានៈជាបេសកជនពិសេសនៃអ្នកតស៊ូផ្ទៃក្នុងនៅប៉េកាំង ហើយជននេះបានត្រឡប់មកកម្ពុជាជា



អៀង សារី ក្នុងបន្ទប់សវនាការ (រូបថត : អ.វ.ត.ក)



ជនជាប់ចោទ អៀង សារី ហៅ "វ៉ាន់" បានចាប់ផ្តើមចូលរួមសកម្មភាពនយោបាយក្នុងទសវត្សរ៍ឆ្នាំ១៩៤០ នៅខណៈដែលខ្លួនជានិស្សិតនៃវិទ្យាល័យព្រះស៊ីសុវត្ថិ ។ នៅឆ្នាំ១៩៥០ ជនជាប់ចោទរូបនេះបានបន្តការសិក្សានៅទីក្រុងបារីសប្រទេសបារាំង ហើយខណៈនោះ អៀង សារី បានក្លាយជាសមាជិកបក្សកុម្មុយនិស្តបារាំងជាមួយ ប៉ុល ពត និងជនជាប់ចោទ ខៀវ សំផន ។ នៅឆ្នាំ១៩៥៧ ជនជាប់ចោទ អៀង សារី បានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានចូលរួមជាមួយគណបក្សបដិវត្តន៍ប្រជាជនកម្ពុជា ។ បន្ទាប់មកនៅឆ្នាំ១៩៦០ ជនជាប់ចោទរូបនេះត្រូវបានបក្សជ្រើសរើសជាសមាជិកគណៈមជ្ឈិម និងជាសមាជិកត្រៀមនៃអចិន្ត្រៃយ៍ក្នុងខែមេសា ឆ្នាំ១៩៧៥ ។ ក្នុងឋាឋានៈជាបេសកជនពិសេស ជនជាប់ចោទរូបនេះបានប្រើប្រាស់មនោសញ្ចេតនាស្នេហាជាតិក្នុងការបំពាក់បំប៉ន និងអូសទាញប្រជាជនកម្ពុជាឲ្យចូលរួមជាមួយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

## ៣) ប្រវត្តិសាវតាររបស់ជនជាប់ចោទ ខៀវ សំផន

ជនជាប់ចោទ ខៀវ សំផន ហៅ "ហែម" ជាសកម្មជនម្នាក់ក្នុងចលនាកុម្មុយនីស្តកម្ពុជា ដែលបានចាប់ផ្តើមចូលក្នុងឆាកនយោបាយចាប់តាំងពីទសវត្សរ៍ឆ្នាំ៥០ នៅប្រទេសបារាំងម៉្លេះ ។ នៅពេលត្រឡប់មកប្រទេសកម្ពុជាវិញ ជននេះបានបង្កើតកាសែតជាភាសាបារាំងដែលមានឈ្មោះថា "*L'Observateur*" (អ្នក

សង្កេតការណ៍) ដោយមានការគាំទ្រនិងផ្តល់ថវិកាដោយសកម្មជនកុម្មុយនីស្តនៃប្រទេសកម្ពុជា ។ ជនជាប់ចោទ ខៀវ សំផន ត្រូវបានតែងតាំងជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការនៃកងទ័ពរំដោះប្រជាជនកម្ពុជា ហើយនៅខែឧសភា ឆ្នាំ១៩៧០ ជននេះត្រូវបានតែងតាំងធ្វើជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ នៅឆ្នាំ១៩៧១ ជនជាប់ចោទរូបនេះបានក្លាយជាសមាជិកបេក្ខជនរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ហើយចន្លោះខែមករានិងមេសា ឆ្នាំ១៩៧៥ ជននេះបានអំពាវនាវឲ្យប្រជាជនទីក្រុងភ្នំពេញក្រោកឡើងតស៊ូរំដោះជាតិនិងបានប្រកាសថា «រណសិរ្សរួបរួមជាតិកម្ពុជា» និង «រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» អាចនឹងកាន់កាប់ក្រុងភ្នំពេញនាពេលឆាប់ៗ ។

ដេញដោលជនជាប់ចោទ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រកាសថា ការសួរដេញដោលនឹងចាប់ផ្តើមមុនគេពីការសាកសួរជនជាប់ចោទ នួន ជា បន្ទាប់មកនឹងបន្តទៅជនជាប់ចោទ អៀង សារី និងចុងក្រោយ គឺជនជាប់ចោទ ខៀវ សំផន ។

### ១) ជនជាប់ចោទ នួន ជា

#### ◆ ការធ្វើកំណត់សម្គាល់របស់ នួន ជា

មុនពេលសួរដេញដោលជនជាប់ចោទ នួន ជា អង្គជំនុំជម្រះបានអនុញ្ញាតឲ្យជនជាប់ចោទធ្វើការបង្ហាញពីជីវិតតស៊ូផ្នែកនយោបាយរបស់ខ្លួនកន្លងមក ។ ក្រោយពីទទួលបានការអនុញ្ញាតិជនជាប់ ចោទ នួន ជា បានចំណាយពេលវេលាស្ទើរតែទាំងស្រុងដើម្បីបង្ហាញពីទឹកចិត្តស្នេហាជាតិ ការស្រឡាញ់យុត្តិធម៌ និងការលះបង់របស់ខ្លួនសម្រាប់ជាតិមាតុភូមិ ។ ជាក់ស្តែង នួន ជា បាន


ខៀវ សំផន ក្នុងបន្ទប់សវនាការ (រូបថត ៖ អ.វ.ត.ក)


នួន ជា ក្នុងបន្ទប់សវនាការ (រូបថត ៖ អ.វ.ត.ក)

### ២) ការសួរដេញដោលជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ពីសំណាក់ចៅក្រមនិងភាគីនៅក្នុងសវនាការ

នៅក្នុងរបៀបវារៈនៃសវនាការស្តីពីការសួរដេញដោល និងពិនិត្យភស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការសួរដេញដោលត្រូវចាប់ផ្តើមពីការសាកសួរជនជាប់ចោទ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ទៅតាមលំដាប់លំដោយ ។

#### ក) ការសួរដេញដោលជនជាប់ចោទ

នៅមុនការចាប់ផ្តើមនៃកិច្ចដំណើរការនីតិវិធីនៃការសួរ

លើកឡើងថា «កាលនៅវ័យកុមារភាព ដែលពេលនោះប្រទេសកំពុងស្ថិតនៅក្រោមអាណានិគមបារាំង ខ្លួនបានឃើញប្រជាជនខ្មែរត្រូវបានគេចាប់ធ្វើបាប និងដាក់ក្នុងមន្ទីរឃុំឃាំង អ្នកមានជិះជាន់និងកេងប្រវ័ញ្ចកម្លាំងពលកម្មអ្នកក្រ» ។ នួន ជា បានបន្ថែមថា មិនត្រឹមតែប្រទេសកម្ពុជាទេ សូម្បីប្រទេសថៃក៏ដូចគ្នាដែរ គឺអ្នកមានជិះជាន់អ្នកក្រ ជាពិសេសជនជាតិចិនជិះជាន់ជនជាតិថៃ ។ ដោយឃើញសភាពបែបនេះ ខ្លួនបានសម្រេចចិត្តចូលរួមជាមួយអង្គការយុវជនប្រជាធិបតេយ្យ និងបន្ទាប់មកចូលបក្សកុម្មុយនីស្តថៃដើម្បីប្រឆាំងនឹងការជិះជាន់ ហើយខ្លួនបានធ្វើសកម្មភាពមួយចំនួនប្រឆាំងនឹងអ្នកកាន់អំណាចមួយចំនួននៅប្រទេសថៃ ។

*នួន ជា បានបន្តទៀតថា នៅថ្ងៃមួយខ្លួនបានទទួលដំណឹងតាមរយៈស្ថានទូតថៃដែលប្រចាំការនៅប្រទេសកម្ពុជាថា ប្រជាជនខ្មែរត្រូវបានពួកបារាំងចាប់វាយដំធ្វើបាប ។ ដោយក្តីអាណិត និងស្រឡាញ់យុត្តិធម៌ ខ្លួនបានសុំការអនុញ្ញាតពីបក្សកុម្មុយនីស្តថៃដើម្បីមកធ្វើសកម្មភាពតស៊ូប្រឆាំងនឹងបារាំងនៅប្រទេសកម្ពុជា ដោយមានការគាំទ្រនឹងផ្តល់ជំនួយដោយបក្សកុម្មុយនីស្តថៃ និងបក្សកុម្មុយនីស្តវៀតណាម ។*

*នួន ជា បានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាមិនមែនកើតឡើងពីកម្លាំងនៅក្នុងស្រុកខ្មែរទាំងស្រុងទេ គឺមានការរួមផ្សំចេញពីអ្នកស្នេហាជាតិដែលមកពីប្រទេសបារាំង (រួមមាន ប៉ុល ពត និង អៀង សារី) បក្សកុម្មុយនីស្តថៃ និងវៀតមិញ ។ ជនជាប់ចោទរូបនេះបានបន្តថា វៀតណាមបានប្រមូលប្រជាជនខ្មែរប្រមាណ២០០០នាក់យកទៅអប់រំនៅប្រទេសវៀតណាម ដើម្បីទុកអ្នកទាំងនោះឲ្យធ្វើជាកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។*

*នួន ជា បានធ្វើការកត់សម្គាល់ពីការសម្លាប់ប្រជាជនខ្មែរថាគឺ “យួនទេដែលសម្លាប់ខ្មែរ មិនមែនខ្មែរសម្លាប់ខ្មែរនោះទេ” ។ ជនជាប់ចោទរូបនេះបានបញ្ជាក់ថា ការសម្លាប់ប្រជាជន ខ្មែរគឺមានការបញ្ជាចេញមកពីហាណូយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហូជីមិញ ហើយកាលបរិច្ឆេទថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាកាលបរិច្ឆេទដែលយួនវាយកម្ពុជា ដោយសារតែកម្ពុជាមិនសុខចិត្តស្ថិតនៅក្រោមការគ្រប់គ្រងរបស់យួន ។*

### ◆ ចម្លើយរបស់ នួន ជា នៅអំឡុងពេលសវនាការប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា

*បន្ទាប់ពីការបញ្ចប់ការធ្វើកំណត់សម្គាល់របស់ជនជាប់ចោទ នួន ជា អង្គជំនុំជម្រះបានចាប់ផ្តើមធ្វើការសួរដេញដោលជនជាប់ចោទរូបនេះ ដោយលោកប្រធានអង្គជំនុំជម្រះ និល ណុន ប្រគល់វេទិកាជូនលោកស្រីចៅក្រមអន្តរជាតិ ស៊ីលវៀ ខាត់វ៉ាយថ៍ ដើម្បីសាកសួរជនជាប់ចោទពីប្រវត្តិរបស់បក្សកុម្មុយនិស្តកម្ពុជា និងតួនាទីរបស់ជនជាប់ចោទនៅមុនពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួររបស់លោកស្រីចៅក្រម ខាត់វ៉ាយថ៍ ជនជាប់ចោទ នួន ជា បានព្យាយាមបង្ហាញពីទឹកចិត្តស្នេហាជាតិរបស់បក្សកុម្មុយនិស្តកម្ពុជាទាំងមូលក្នុងការតស៊ូរំដោះប្រទេសជាតិចេញពីស្ថានភាពមួយដែលខ្លួនគិតថា ជាសង្គមមានការជិះជាន់ដោយវណ្ណៈសក្តិភូមិ និងកំពុងស្ថិតនៅក្រោមការជ្រៀតជ្រែកកាន់កាប់ដោយប្រទេសវៀតណាម ។ នួន ជា បានលើកឡើងថា ក្រោយពីបក្សកុម្មុយនីស្តឥណ្ឌូចិនបានរលាយបក្សប្រជាជនបដិវត្តន៍ខ្មែរ បក្សប្រជាជនបដិវត្តន៍ឡាវ និងបក្សពលករវៀតណាមត្រូវបានបង្កើតឡើង ។ តែបក្សប្រជាជនបដិវត្តន៍ខ្មែរ និងបក្សប្រជាជនបដិវត្តន៍ឡាវមិនមានឯករាជ្យពីវៀតណាមឡើយ ដោយសារមាគ៌ា*



នួន ជា

*យុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីរបស់បក្សទាំងពីរត្រូវអនុលោមតាមបក្សពលករវៀតណាម ។ ជនជាប់ចោទ នួន ជា បានបន្ថែមទៀតថា រាល់ការអនុវត្ត ឬសម្រេចធ្វើផ្សេងៗរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ គឺត្រូវបានការអនុញ្ញាតិ ឬសារណែនាំមកពីបក្សពលករវៀតណាម ។ ដូចនេះដើម្បីកាត់បន្ថយឥទ្ធិពលរបស់វៀតណាមមកលើបក្សប្រជាជនបដិវត្តន៍ខ្មែរ នួន ជា និង ប៉ុល ពត បានទទួលបន្ទុកក្នុងការបង្កើត “មាគ៌ាយុទ្ធសាស្ត្រ” និង “មាគ៌ាយុទ្ធវិធី” របស់បក្សដាច់ដោយឡែកមួយ ដោយមានការសម្របសម្រួលពី ទូ*

សាមុត ដែលមាននាទីជាលេខាបក្សនាពេលនោះ ។ នួន ជា បានបញ្ជាក់ថា វៀតណាមមានការមិនពេញចិត្តចំពោះបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលបានបង្កើតមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីដោយមិនបានសួរយោបល់របស់ខ្លួនឡើយ ។ ដូចនេះ វៀតណាមបានចាត់តាំងបុគ្គលមួយចំនួនឲ្យបន្ទំខ្លួនដើម្បីបំផ្លិចបំផ្លាញមាគ៌ារបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ។ ទោះបីជាយ៉ាងនេះក្តី មាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីរបស់ខ្លួនបានទទួលការគាំទ្រពីប្រទេសចិន ហើយប្រទេសចិនថែមទាំងបានផ្តល់ជំនួយឲ្យអនុវត្តមាគ៌ាទាំងពីរ


(ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នេះទៀតផង ។ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា ការណ៍ដែលបក្សប្រជាជនបដិវត្តន៍ខ្មែរប្តូរឈ្មោះមកជាបក្សពលករខ្មែរ គឺដោយសារតែខ្លួនមានបំណងកាត់ផ្តាច់ពីឥទ្ធិពលរបស់បក្សពលករវៀតណាម ។ ទោះបីមានការផ្លាស់ប្តូរឈ្មោះបក្សក្តី មាគ៌ានយោបាយរបស់បក្សមិនត្រូវបានផ្លាស់ប្តូរឡើយ ។

## ការបង្កើតមាគ៌ានយោបាយរបស់បក្ស

ពាក់ព័ន្ធនឹងការបង្កើតមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីរបស់បក្ស ជនជាប់ចោទ នួន ជា បានលើកឡើងយ៉ាងលម្អិតថា ក្នុងការរៀបចំនូវមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីនេះគឺ ប៉ុល ពត ជាអ្នកទទួលបន្ទុកក្នុងការតាមដានសភាពការណ៍នៅតាមទីក្រុង ចំណែកខ្លួនជាអ្នកទទួលបន្ទុកទាក់ទងជាមួយកម្មាភិបាលចាស់ពីសម័យក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ។ ក្នុងការអនុវត្តភារកិច្ចនេះ ខ្លួនទាក់ទងបានភូមិភាគពាយ័ព្យ ភូមិភាគនិរតី និងបាត់ដំបង ចំណែកឯ ប៉ុល ពត ទាក់ទងបានកម្មាភិបាលភូមិភាគបូព៌ាគឺ ឈ្មោះ សោ ភឹម ។ ក្រោយពីទាក់ទងបានកម្មាភិបាលទាំងនេះ នួន ជា បានស្នើឲ្យស៊ើបសួរពីសភាពការណ៍នៅតាមជនបទ ចំណែកឯ ប៉ុល ពត ស៊ើបសួរសភាពការណ៍នៅទីក្រុង ។ នួន ជា យល់ថា នៅជនបទភាគច្រើន ៨៥ភាគរយជាកសិករក្រីក្រដែលត្រូវបានជិះជាន់ដោយមេភូមិ មេឃុំ ប៉ូលីស ទាហ៊ាន និងអ្នកមាន ។ល។ រីឯ ប៉ុល ពត ក្តាប់បានសភាពការណ៍ថា មានមន្ត្រីរាជការតូចតាចមួយចំនួនដែលមានជីវៈភាពខ្វះខាត ។ នួន ជា បានសង្កត់ធ្ងន់ថា កសិករក្រីក្រ និងមន្ត្រីរាជការដែលមានឋានៈតូចតាចទាំងនេះ ដែលនឹងត្រូវមើលឃើញកម្លាំងដែលត្រូវទាក់ទាញ (« នេះយើងត្រូវឃើញកម្លាំង») ។ នួន ជា បានលើកឡើងថា មុននឹងធ្វើមាគ៌ានយោបាយ បក្សបានធ្វើការវិភាគអំពីធាតុពិតនៃសង្គមកម្ពុជានៅពេលនោះ ។ បន្ទាប់ពីសិក្សាអំពីសភាពការណ៍នៅពេលនោះ បក្សពិនិត្យឃើញថា សង្គមកម្ពុជាគឺជាសង្គមពាក់កណ្តាលអាណានិគម និងពាក់កណ្តាលសក្តិភូមិ ។ ជនជាប់ចោទបានបន្ថែមថា "សង្គមកម្ពុជាជាសង្គមពាក់កណ្តាលអាណានិគម ពីព្រោះវានៅមានកម្មែលអាណានិគមនៅឡើយ វាមិនទាន់ឯករាជ្យសុទ្ធសាធនៅឡើយទេ" ។ ហើយជាសង្គមពាក់កណ្តាលសក្តិភូមិ ពីព្រោះវាមានរបបនាយទុន ហើយវាមិនមែនសក្តិភូមិទាំងដុលទេ ។ ដូចនេះបើធាតុពិតនៃសង្គមកម្ពុជា ជាសង្គមពាក់កណ្តាលអាណានិគមពាក់កណ្តាលសក្តិភូមិ យើងត្រូវធ្វើបដិវត្តន៍ជាតិប្រជាធិបតេយ្យ" ។ នួន ជា បានបញ្ជាក់ថា ធាតុពិតរបស់បដិវត្តន៍កម្ពុជានៅពេលនោះគឺជា "បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ" ។ ពាក្យ "បដិវត្តន៍ប្រជាជាតិ" មានន័យថា គឺកម្ចាត់ឥទ្ធិពលរបស់អាណានិគម ពាក់កណ្តាលអាណានិគម ចំណែកឯពាក្យ "ប្រជាធិបតេយ្យ" គឺកម្ចាត់ឥទ្ធិពលរបស់ពួកសក្តិភូមិម្ចាស់ដី ។ ដូចនេះសត្រូវរបស់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យគឺ "កម្មែលបរទេស ដែលនៅប្រើអំណាចអាជ្ញាមកលើ

ប្រជាជនខ្មែរ នេះគឺជាសត្រូវដែលត្រូវដុះលាង ។ ឯពាក់កណ្ដាលសក្តិភូមិគឺទាមទារឲ្យកសិករតស៊ូបន្ថយឈ្នួលស្រែ ការប្រាក់ បុលបណ្ដាក់» ។ នួន ជា បានបញ្ជាក់ថា «ដូចនេះមិនមែនយកមនុស្សជាសត្រូវទេខ្ញុំសូមជម្រាប គឺយកការប្រព្រឹត្តរបស់គេជាសត្រូវ» ។ «តើនរណាជាកម្លាំងបដិវត្តន៍?» នួន ជា បានបកស្រាយថាៈ

«ពេលនោះគឺកសិករក្រ កសិករកណ្ដាលថ្នាក់ក្រោម ក្រោមសម្ព័ន្ធភាពរបស់កម្មករ កសិករ ជាកម្លាំងបដិវត្តន៍របស់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ខ្ញុំសូមជម្រាបឲ្យច្បាស់ ឯក្រៅពីនេះគឺអ្នកដែលមានស្មារតីស្នេហាជាតិ ស្មារតីប្រជាធិបតេយ្យក៏យើងត្រូវប្រមូលដែរ យើងមិនបដិសេធអ្នកណាទេ ដូចជាកសិករកណ្ដាល ឬកសិករមាន ទោះបីជាធ្លាប់មានការជិះជាន់ខាងបុលបណ្ដាក់ខ្លះ ក៏យើងមិនចាត់ទុកជាសត្រូវដែរ ត្រូវប្រមូលកម្លាំងអស់នេះមកចូលក្នុងបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ។»

នួន ជា បានបន្ថែមថា នៅក្នុងការកសាងកម្លាំងបដិវត្តន៍ បក្សបានបង្កើតមាគ៌ាយុទ្ធវិធី ដែលជាទូទៅហៅថា «មាគ៌ារណៈសិរ្សរួបរួមជាតិ» ដោយរណៈសិរ្សរួមរួបរួមជាតិនេះ ធ្វើការប្រមូលកម្លាំងគ្រប់ជនជាតិទាំងអស់ដែលមានស្មារតីជាតិ ស្មារតីស្នេហាប្រជាជន មិនរើសអើងពីអតីតកាលមិនថាជនជាតិភាគតិច មិនថាជនជាតិភាគច្រើនចូលមករួបរួមគ្នាជាកម្លាំងមហាសាមគ្គីជាតិ ដើម្បីតស៊ូកម្ចាត់របបពាក់កណ្ដាលអាណានិគម ពាក់កណ្ដាលសក្តិភូមិ ។ ចំណែកវិធីសាស្ត្រនៃការធ្វើបដិវត្តន៍ គឺចាប់ផ្ដើមធ្វើពីចុងកាត់មាត់ញក រាលដាលទៅទីប្រជុំជន ទៅតាមទីរួមស្រុក គឺប្រៀបដូចជាដំណក់ប្រេង ដែលកាលនោះខ្លួនបានប្រើពាក្យថា «ធ្វើបដិវត្តន៍របៀបដំណក់ប្រេង» ហើយធ្វើការតស៊ូដោយស្របច្បាប់ ពាក់កណ្ដាលស្របច្បាប់ មិនស្របច្បាប់ តស៊ូទាំងនយោបាយ តស៊ូទាំងសេដ្ឋកិច្ច តស៊ូទាំងវប្បធម៌ ហើយបើចាំបាច់ត្រូវតស៊ូទាំងអាវុធនិងនយោបាយរួមផ្សំគ្នា ។ ជនជាប់ចោទរូបនេះបានលើកឡើងពាក់ព័ន្ធនឹងពាក្យស្លោកក្នុងការធ្វើបដិវត្តន៍ នួន ជា និយាយថា «ដើម្បីសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ តស៊ូយូរអង្វែង លំបាកវេទនា ខ្លួនទីពឹងខ្លួន ខ្លួនសម្រេចវាសនាជាតិខ្លួនដោយខ្លួនឯង បើចាំបាច់ក៏យើងមានការទាក់ទងជាមួយមិត្តប្រទេសជាមិត្តដែលស្នេហាសន្តិភាព ស្នេហាយុត្តិធម៌ផងដែរ ហើយការតស៊ូនេះដើម្បីការពារជាតិ បូរណភាពដែនដីនៃប្រទេសយើង អានេះពាក្យស្លោក» ។

នួន ជា បានបញ្ជាក់ថា ក្រោយពីបក្សមានមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធី ចលនាបដិវត្តន៍ក៏ចេះតែមានការរីកចម្រើនជាលំដាប់រហូតដល់វាយឈ្នះរបប លន់ នល់ ឆ្នាំ១៩៧៥ ។

## ការចូលរួមក្នុងចលនាបដិវត្តន៍

បន្ទាប់ពីត្រឡប់មកពីប្រទេសថៃក្នុងឆ្នាំ១៩៥១វិញ ជនជាប់ចោទ នួន ជា បានចូលរួមយ៉ាងសកម្មក្នុងចលនាបដិវត្តន៍នៅកម្ពុជា ។ ក្រោយពេលមកដល់ប្រទេសកម្ពុជាភ្លាម នួន ជា បានចាប់ផ្ដើមធ្វើសកម្មភាពបះបោរប្រជាជនឲ្យប្រឆាំងនឹងការជិះជាន់របស់បារាំងតាមរយៈការសរសេរអត្ថបទកាសែតមួយចំនួន ។ សកម្មភាពទាំងនេះត្រូវបានគាំទ្រ និងផ្ដល់ជំនួយដោយបក្សកុម្មុយនីស្តថៃ និងបក្សកុម្មុយនីស្តវៀតណាម ។ បន្ទាប់មកនៅឆ្នាំ១៩៥៣ នួន ជា បានទៅទទួលវគ្គបណ្ដុះបណ្ដាលផ្នែកនយោបាយនៅប្រទេសវៀតណាមចំនួនពីរឆ្នាំ ។ វគ្គសិក្សានៅពេលនោះផ្ដោតជាសំខាន់ទៅលើ «ការប្រយុទ្ធប្រឆាំងនឹងផ្នែកសតិអារម្មណ៍» ។ ក្រោយពីរៀនចប់នៅវៀតណាម នួន ជា បានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានចូលរួមជាមួយ ប៉ុល ពត ដើម្បីជួយកិច្ចការរបស់ ទូ សាមុត ។ ក្រោយពី ទូ សាមុត ណែនាំឲ្យបង្កើតមាគ៌ានយោបាយរបស់បក្ស នួន ជា និង ប៉ុល ពត មានតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលកសាងកម្លាំង និងបំផុសបំផុលប្រជាជនឲ្យចូលរួមធ្វើបដិវត្តន៍ ។ បន្ថែមលើនេះ នៅពេលដែល ប៉ុល ពត និង អៀង សារី ទៅតាំងទីស្នាក់ការនៅព្រំដែនវៀតណាម ក្រោយពីមានការប្រកាសពីបុគ្គលឆ្វេងនិយមចំនួន៣៨នាក់ ជនជាប់ចោទ នួន ជា គឺជាបុគ្គលសំខាន់ម្នាក់ដែលមាននាទីតាមដានសភាពការណ៍នៅទីក្រុងភ្នំពេញ ហើយរាយការណ៍ទៅ ប៉ុល ពត ។ តួនាទីសំខាន់មួយទៀតរបស់ជនជាប់ចោទ នួន ជា គឺការអប់រំនយោបាយរបស់បក្សទៅដល់កម្មាភិបាលថ្នាក់ក្រោម ។ នួន ជា និយាយថា ខ្លួនមានតួនាទីសំខាន់ក្នុងការអប់រំនយោបាយដល់កម្មាភិបាលថ្នាក់ក្រោមៗ ដោយផ្អែកលើទស្សនាវដ្ដីទង់បដិវត្តន៍ និងឯកសារមួយចំនួនទៀតដូចជាឯកសារលោកទស្សនៈ សង្គមទស្សនៈ ឯកសារស្ដីពីការ

បែងចែកវណ្ណៈក្នុងសង្គមដែលខ្លួនបានអនុវត្តតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ ។

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ជនជាប់ ចោទ នួន ជា បានបញ្ជាក់ថា នៅពាក់កណ្តាលឆ្នាំ១៩៧៤ មានកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមមិនពេញអង្គមួយដើម្បីធ្វើការសម្រេចបញ្ហាជម្លៀសនេះ ។ នៅក្នុងកិច្ចប្រជុំនោះមិនមានវត្តមានជនជាប់ចោទ ខៀវ សំផន និង អៀង សារី ។ ព្រោះពេលនោះ អៀង សារី កំពុងស្ថិតនៅឯបរទេស ។ ចំណែកឯ ខៀវ សំផន មិនទាន់មានសិទ្ធិសម្រេចក្នុងការជម្លៀសប្រជាជនឡើយ ដោយសារពេលនោះ ជនជាប់ចោទនេះមិនទាន់ក្លាយជាសមាជិករបស់គណៈមជ្ឈិមឬរបស់គណៈអចិន្ត្រៃយ៍ឡើយ ។ ជនជាប់ចោទ នួន ជា បានបន្ថែមថា ក្រោយពីការបញ្ចប់កិច្ចប្រជុំស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សេចក្តីសម្រេចនេះត្រូវបានផ្សព្វផ្សាយទៅតាមភូមិភាគនីមួយៗ ។ ជនជាប់ចោទ នួន ជា បានលើកឡើងថា ស្ថានភាពរស់នៅទីក្រុងភ្នំពេញនៅពេលនោះមានការលំបាកវេទនា ប្រជាជនមួយចំនួនធំហូបមិនគ្រប់គ្រាន់ ហើយមានមួយចំនួនទៀតបានស្លាប់ដោយសារអត់អាហារបរិភោគ ។ ដូចនេះការជម្លៀសទៅតាមជនបទ គឺជាការល្អព្រោះនៅ ទីនោះប្រជាជនមានជីវៈភាពគ្រាន់បើ ហើយថែមទាំងមានដីសម្រាប់ធ្វើកសិកម្មទៀតផង ។ ហើយម្យ៉ាងវិញទៀតក៏ដើម្បីតាមដានសភាពការណ៍និងបញ្ចៀសការសម្លាប់ប្រជាជន ដែលពេលនោះវៀតណាមមានបំណងវាយចូលទីក្រុងភ្នំពេញ ។

ជនជាប់ចោទ នួន ជា បានលើកឡើងថា នៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្លួនបានប្រាប់ដល់កម្មាភិបាលថ្នាក់ក្រោមៗថា ប្រជាជនដែលធ្លាប់រស់នៅទីក្រុងភ្នំពេញឲ្យធ្វើការតិចតួចបាន ហើយព្រោះពួកគេមិនធ្លាប់ធ្វើការធ្ងន់ៗ ហើយឲ្យហូបមួយថ្ងៃបីពេល រួមទាំងឲ្យបង្អែមហូប១ដងក្នុងមួយសប្តាហ៍ទៀតផង បន្ថែមលើនេះខ្លួនថែមទាំងបានអប់រំដល់អ្នកនៅមូលដ្ឋានមិនឲ្យមានការរើសអើងទៅលើប្រជាជនថ្មីឡើយ ។ផ្ទុយទៅវិញជនជាប់ចោទ នួន ជា បានលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាគឺ ជាបក្សស្នេហាជាតិ លះបង់អ្វីៗដើម្បីជាតិ ហើយមិនដែលសម្លាប់ប្រជាជនខ្មែរឡើយ អ្នកដែលសម្លាប់ប្រជាជន និងធ្វើបាបប្រជាជន គឺអ្នកមានសមាសភាពមិនល្អនៅក្នុងសហករណ៍ដែលធ្វើសកម្មភាពដើម្បីបំផ្លាញបដិវត្តន៍ ។

## ការប្រជុំជម្លៀសប្រជាជន

ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងទីប្រជុំជនផ្សេងៗ ជនជាប់ចោទ នួន ជា បានលើកឡើងថា នៅពេលកងទ័ពបដិវត្តន៍វាយចូលកាន់កាប់បានទីក្រុង ឬទីប្រជុំជនណាមួយ ប្រជាជនដែលរស់នៅទីក្រុង ឬទីប្រជុំជននោះខ្លះត្រូវបានជម្លៀស ហើយខ្លះទៀតមិនត្រូវបានជម្លៀស គឺអាស្រ័យទៅលើស្ថានភាពកសិកម្មអំណោយផល ។ សេចក្តីសម្រេចក្នុងការជម្លៀសនេះចេញមកពីគណៈភូមិភាគនៃតំបន់នោះ ដែលគណៈភូមិភាគនោះបានទទួលអំណាចនេះពីគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ។

នៅក្នុងការសួរដេញដោលពីការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា អង្គជំនុំជម្រះបានផ្តោតជាសំខាន់ទៅលើទំនាក់ទំនងរវាងការបង្កើត “កងកម្លាំងពិសេស” ដែលត្រូវបានបង្កើតឡើងដើម្បីការពារសន្តិសុខឲ្យកម្មាភិបាលខ្មែរក្រហម និងការប្តូរឈ្មោះរបស់កងកម្លាំងនេះមកជា“កងទព័បដិវត្តន៍កម្ពុជា” ។ ឆ្លើយតបទៅនឹងបញ្ហានេះ នួន ជា បានលើកឡើងថា ពួកកាន់អំណាចប្រតិកិរិយា លន់ នល់ បានចាប់ប្រជាជន និងកម្មាភិបាលខ្មែរក្រហមដាក់គុកដោយគ្មានហេតុផល ដែលការធ្វើដូចនេះអាចនឹងធ្វើឲ្យបដិវត្តន៍រលាយ ។ដូច្នេះត្រូវមានកងកម្លាំងពិសេសដើម្បីការពារសុវត្ថិភាពឲ្យកម្មាភិបាលខ្មែរក្រហមនៅពេលពួកគេដើរធ្វើការ ព្រោះខ្លាចកងទ័ពរបស់ លន់ នល់ ចាប់កម្មាភិបាលទាំងនោះ ។ កងកម្លាំងពិសេសនេះត្រូវបានជ្រើសរើសចេញពីកូនកសិករ ហើយដោយប្រើអាវុធដូចជាកាំបិទ ពូថៅ ដំបង ។ល ។ ដើម្បីតតាំងនៅពេលមានការចាប់កម្មាភិបាលខ្មែរក្រហម ហើយកងកម្លាំងទាំងនេះក៏មានភារកិច្ចស្វែងរកគិញផងដែរនៅពេលដែលមានការប្រជុំរបស់ពួកកម្មាភិបាលខ្មែរក្រហម ។

## ការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា

ពាក់ព័ន្ធទៅនឹងការបង្កើតកងទ័ពបដិវត្តន៍ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា បក្សបានកំណត់យកថ្ងៃទី១៧ ខែមករា ឆ្នាំ ១៩៦៨ គឺជាកាលបរិច្ឆេទនៃការបង្កើតកងទ័ពបដិវត្តន៍ ។ ក្រោយពីចលនាបោះបោរនៅសំឡូត កងទ័ពរបស់ លន់ នល់ បានទៅបង្ក្រាប

យ៉ាងសាហាវឃោរឃៅ ។ ដោយការភ័យខ្លាចនូវការបង្រ្កាបនេះ ប្រជាជននៅសំឡូតបានរត់ទៅរស់នៅតាមព្រៃភ្នំ ហើយបន្ទាប់មកអ្នកទាំងនោះមានគ្នាប្រហែល៧នាក់ បាននាំគ្នាទៅវាយប្រហារលើប៉ុស្តិ៍ប៉ូលិសនៅបាយដំរាំ ហើយបានរឹបអូសយកអាវុធបានមួយចំនួន ។ បន្ទាប់ពីការវាយនៅបាយដំរាំនេះ កងកម្លាំងទាំងនោះបានបន្តវាយជាបន្តបន្ទាប់ទៅលើកងទ័ពរបស់ លន់ នល់ រហូតទៅដល់ ១៧ខេត្ត ។

នៅអំឡុងពេលនៃការសាកសួរដេញដោលនេះ មានការកត់សម្គាល់ឃើញថា ជនជាប់ចោទ នួន ជា បានព្យាយាមឆ្លើយតបស្ទើរគ្រប់សំណួរដែលចៅក្រមចោទសួរមកលើខ្លួន ដោយរៀបរាប់បានយ៉ាងក្បោះក្បាយពីប្រវត្តិសកម្មភាពតស៊ូរបស់ខ្លួន ។ នៅពេលមានការសាកសួរដេញដោលពីសំណាក់សហព្រះរាជអាជ្ញាដែលជាអ្នកចោទប្រកាន់ដាក់បន្ទុកមកលើខ្លួន ជនជាប់ចោទ នួន ជា ភាគច្រើនបានបដិសេធ ឬអះអាងថា ខ្លួនមិនយល់អំពីអ្វីដែលសហព្រះរាជអាជ្ញាចង់សួរមកលើខ្លួនឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ជនជាប់ចោទ នួន ជា បានព្យាយាមបដិសេធម្តងហើយម្តងទៀតទៅលើភស្តុតាងដែលសហព្រះរាជអាជ្ញាបានបង្ហាញនៅអំឡុងពេលសវនាការ ។

## ២) ជនជាប់ចោទ អៀង សារី

ក្រោយពីការសួរដេញដោលជនជាប់ចោទ នួន ជា អំពីប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា និងប្រវត្តិសាវតាររបស់ជនជាប់ចោទរូបនេះ លោកចៅក្រម និល ណុន បានបន្តសួរជនជាប់ចោទ អៀង សារី ដោយផ្តោតតែទៅលើឈ្មោះ និងប្រវត្តិរូបរបស់ជនជាប់ចោទរូបនេះតែប៉ុណ្ណោះ ។ ដោយឡែក សំណួរផ្សេងៗពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ជនជាប់ ចោទ អៀង សារី បានរក្សាសិទ្ធិមិនធ្វើការឆ្លើយតប ។ នៅពេលលោកចៅក្រម និល ណុន ស្នើឲ្យជនជាប់ចោទរៀបរាប់ពីប្រវត្តិសិក្សារបស់ខ្លួនមេធាវីរបស់ជនជាប់ចោទ អៀង សារី គឺលោក ម៉ៃខល ខាណាវ៉ាស់ បានធ្វើការជំទាស់ដោយមិនឲ្យកូនក្តីរបស់ខ្លួនឆ្លើយតបទៅនឹងសំណួររបស់លោកប្រធានអង្គជំនុំជម្រះ ដោយមេធាវីបានលើកឡើងថា នៅខែតុលា ឆ្នាំ២០១១ កូនក្តីរបស់ខ្លួនបានដាក់ពាក្យស្នើសុំមួយទៅអង្គជំនុំជម្រះសាលាដំបូង ដោយសុំរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលចោទសួរដោយភាគីរួចហើយ ។ មេធាវីបានបញ្ជាក់ថា ចៅក្រមអាចសួរសំណួរទូទៅដែលពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណរបស់កូនក្តីរបស់ខ្លួនតែប៉ុណ្ណោះ ។ លោកមេធាវី ខាណាវ៉ាស់ ក៏បានធ្វើសំណើទៅអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនអាននូវសេចក្តីថ្លែងការណ៍ស្តីពីការ«រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប» នៅក្នុងសវនាការជាសាធារណៈ ដើម្បីជៀសវាងការសំណួរណាមួយមកលើកូនក្តីរបស់ខ្លួនបន្តទៀត ដោយអះអាងថា ការរក្សាសិទ្ធិមិនធ្វើសក្ខីកម្ម ឬមិនឆ្លើយនឹងសំណួររបស់ភាគីនោះ គឺជាសិទ្ធិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ។ យោងទៅលើសំណើនេះ អង្គជំនុំជម្រះបានសម្រេចឲ្យជនជាប់ចោទ អៀង សារី អានសេចក្តីថ្លែងការណ៍របស់ខ្លួនស្តីពីគោលជំហរក្នុងការមិនឆ្លើយតបទៅនឹងសំណួរនៅពេលសវនាការ ។ ជនជាប់ចោទ អៀង សារី បានថ្លែងថា :

> «ខ្ញុំបាទសូមប្រើប្រាស់សិទ្ធិរបស់ខ្ញុំក្នុងរដ្ឋធម្មនុញ្ញ ដោយរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរទាំងឡាយនាពេលនេះ ។ សិទ្ធិនេះមានចែងក្នុងមាត្រា ៣១ និង៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំបាទមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុងការជំនុំជម្រះទាំងមូល ហើយមិនមានបំណងឆ្លើយតបនឹងសំណួរណាមួយឡើយ» ។

ចប់សេចក្តីថ្លែងការណ៍នេះភ្លាម លោកមេធាវី ខាណាវ៉ាស់ បានងើបឈរ និងបញ្ជាក់បន្ថែមជូនទៅអង្គជំនុំជម្រះថា កូនក្តីរបស់ខ្លួននឹងប្រើសិទ្ធិនេះដោយមិនឆ្លើយតបទៅនឹងសំណួរណាមួយនៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ រួមទាំងចំណុចទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផងដែរ ។

## ៣) ជនជាប់ចោទ ខៀវ សំផន

### ◆ ខៀវ សំផន ស្នើសុំធ្វើសេចក្តីថ្លែងការណ៍និងបដិសេធមិនឆ្លើយសំណួររបស់ភាគី

ក្រោយពេលជនជាប់ចោទ អៀង សារី បានប្រើប្រាស់សិទ្ធិមិនធ្វើសក្ខីកម្មនៅក្នុងសវនាការ អង្គជំនុំជម្រះបានផ្តើមបន្តនីតិវិធីរបស់ខ្លួន ដោយធ្វើការចោទសួរទៅលើជនជាប់ចោទ ខៀវ សំផន ។

មុនពេលនៃការចាប់ផ្តើមសំណួរ មេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ ខៀវ សំផន ដែលទើបនឹងទទួលស្គាល់ដោយអង្គជំនុំជម្រះកាលពីថ្ងៃទី២១ ខែវិច្ឆកា ឆ្នាំ២០១១ កន្លងមក គឺលោក អាកធូរ វែកកែន (Arthur Vercken) បានងើបឈរ និងបញ្ជាក់ទៅអង្គជំនុំជម្រះអំពីគោលបំណងរបស់កូនក្តីរបស់ខ្លួនថា កូនក្តីរបស់ខ្លួននឹងឆ្លើយតបត្រឹមតែសំណួរទាំងឡាយដែលចោទប្រកាន់មកលើខ្លួននៅក្នុងដីកាដំណោះស្រាយដែលបានអានដោយក្រឡាបញ្ជីកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ កន្លងមកតែប៉ុណ្ណោះ ។ ការសួរដេញដោលទៅលើជនជាប់ចោទ ខៀវ សំផន ចាប់ផ្តើមដោយ ខេត្តស្វាយរៀង ។ មានឪពុកឈ្មោះ ខៀវ ឡុង និងមានម្តាយឈ្មោះ លី គង់ ហើយមានបងប្អូនទាំងអស់១២នាក់ និងមានប្រពន្ធឈ្មោះ សូ សុជាតិ មាន កូន៤នាក់ ។ កាលនៅវ័យក្មេងខ្លួនបានសិក្សានៅបឋមសិក្សា និងអនុវិទ្យាល័យនៅក្នុងខេត្តកំពង់ចាម និងបន្ទាប់មកខ្លួនបានផ្លាស់មករៀននៅទីក្រុងភ្នំពេញនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ នៅចន្លោះឆ្នាំ១៩៥១ និងឆ្នាំ១៩៥៣ ខ្លួនបានធ្វើជាគ្រូបង្រៀនដើម្បីផ្គត់ផ្គង់ជីវភាព និងសិក្សាផ្នែកច្បាប់នៅឯទីក្រុងភ្នំពេញរហូតដល់ទទួលបានអាហារូបករណ៍ទៅសិក្សានៅឯប្រទេសបារាំងនៅឆ្នាំ១៩៥៣ និងត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៥៨ ។ នៅក្រោយ




ប្រធានអង្គជំនុំជម្រះលោកចៅក្រម និល ណុន ដោយផ្តោតទៅលើប្រវត្តិរូប និងប្រវត្តិសិក្សារបស់ជនជាប់ចោទរូបនេះ ។ ជនជាប់ចោទ ខៀវ សំផន បានជម្រាបទៅតុលាការថា ក្រៅពីឈ្មោះ ខៀវ សំផន ខ្លួនមានឈ្មោះបដិវត្តមួយទៀតថា ហែម ហើយមិនដែលមានឈ្មោះ ខាង ដូចជាការលើកឡើងរបស់ជនជាប់ចោទ ឌុច ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ខៀវ សំផន បានទទួលស្គាល់ថាខ្លួនធ្លាប់បានប្រើឈ្មោះ ណាន នៅពេលដែលខ្លួនរស់នៅ ភូមិភាគនិរតី ។ ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ជូនទៅអង្គជំនុំជម្រះថា ខ្លួនកើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ការសួរដេញដោលពីប្រវត្តិរូប និងប្រវត្តិសិក្សាពីសំណាក់លោកប្រធានអង្គជំនុំជម្រះ ជនជាប់ចោទ ខៀវ សំផន បានស្នើសុំទៅអង្គជំនុំជម្រះដើម្បីអានសេចក្តីថ្លែងការណ៍របស់ខ្លួនដែលបានត្រៀមទុករួចជាស្រេច និងបញ្ជាក់ ជូនទៅអង្គជំនុំជម្រះថា ខ្លួននឹងមិនធ្វើការឆ្លើយតបនឹងសំណួរទាំងឡាយដែលចោទសួរដោយគូភាគីមកលើខ្លួនឡើយ រហូតដល់ពេលដែលសហព្រះរាជអាជ្ញាបង្ហាញភស្តុតាងដែលចោទប្រកាន់ប្រឆាំងនឹងខ្លួន ។ ប៉ុន្តែមុននឹងអនុញ្ញាតឲ្យជនជាប់ចោទ ខៀវ សំផន អានសេចក្តីថ្លែងការណ៍របស់ខ្លួនប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម និល ណុន បានអានបទចោទ

ប្រកាន់ទាំងឡាយ និងបង្ហាញពីសិទ្ធិដែលជនជាប់ចោទមានទៅដល់ជនជាប់ចោទ ខៀវ សំផន ។ បន្ទាប់មកអង្គជំនុំជម្រះក៏បានអនុញ្ញាតឲ្យជនជាប់ចោទ ខៀវ សំផន ចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួនដែលប្រើប្រាស់រយៈពេលប្រមាណជាង១ម៉ោង និង៣០នាទី ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន ជនជាប់ចោទ ខៀវ សំផន បានព្យាយាមធ្វើការឆ្លើយតបទៅតាមលំដាប់លំដោយចំពោះរាល់ចំណុចទាំងឡាយដែលក្រឡាបញ្ជីបានអានចេញពីដីកាដំណោះស្រាយនៅត្រង់កថាខណ្ឌទី១១២៦ កថាខណ្ឌទី១១២៨-១១២៩ និងកថាខណ្ឌទី១៥៩៨-១៦០០ ដែលចោទប្រកាន់ប្រឆាំងនឹងខ្លួន ។ នៅក្នុងសេចក្តីថ្លែងការណ៍នោះ ជនជាប់ចោទ ខៀវ សំផន បានរៀបរាប់យ៉ាងលម្អិតពីសកម្មភាពសំខាន់ៗរបស់ខ្លួនពីរវាងឆ្នាំ១៩៥៣រហូតដល់ឆ្នាំ១៩៧៥ ដោយបែងចែកទៅតាមលំដាប់នៃព្រឹត្តិការណ៍នីមួយៗ ដែលចាប់ផ្តើមអត្ថាធិប្បាយពីរយៈកាលដែលខ្លួនរៀននៅប្រទេសបារាំង មូលហេតុដែលនាំឲ្យខ្លួនរត់ចូលក្នុងព្រៃនៅឆ្នាំ១៩៦៧ សកម្មភាពក្រោយការផ្ទុះរដ្ឋប្រហារឆ្នាំ១៩៧០ និងតួនាទីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។

**សកម្មភាពអំឡុងពេលរៀននៅប្រទេសបារាំង និងក្រោយពេលត្រឡប់មកវិញ**

ឆ្លើយតបនឹងការចោទប្រកាន់មកលើខ្លួនដែលមាននៅក្នុងកថាខណ្ឌ ១១២៦ និង១១៥៩ នៃដីកាដំណោះស្រាយទាក់ទងនឹងសកម្មភាពនៅពេលដែលរៀននៅស្រុកបារាំង ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា ពេលដែលខ្លួននៅប្រទេសបារាំងខ្លួនមិនដែលបានជួបនឹង ប៉ុល ពត ទេ គឺជួបតែ អៀង សារី ប៉ុណ្ណោះ ។ នៅទីនោះ ខៀវ សំផន បានជួបនឹងមិត្តភក្តិចាស់របស់ខ្លួនម្នាក់ដែលធ្លាប់រៀនជាមួយគ្នានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ឈ្មោះ ឱក សុគន្ធ បានស្នើឲ្យខ្លួនចូលរួមក្នុងចលនា ម៉ាកស៊ីស ប៉ុន្តែខ្លួនបានឆ្លើយតបទៅវិញថា ខ្លួនគ្រាន់តែចង់បានឯករាជ្យប៉ុណ្ណោះ ហើយខ្លួនមិនស្គាល់ម៉ាកស៊ីសអ្វីទេ ។ ពេលនោះលោក ឱក សុគន្ធ បានប្រាប់ខ្លួនថា ម៉ាកស៊ីសនេះហើយដែលអាចនាំទៅរកឯករាជ្យសម្រាប់ប្រទេសកម្ពុជា ។ ជនជាប់ចោទ ខៀវ សំផន បានបន្តថា ក្រោយមកខ្លួនក៏បានចូលរួមពិនិត្យអង្កេតនៅក្នុងចលនានេះដើម្បីកុំឲ្យគេថាខ្លួនជាមនុស្សកំសាក ។ តែដោយសារស្ថានភាពនយោបាយតឹងតែងនៅពេលនោះ ខ្លួនក៏បានសម្រេចចិត្តផ្លាស់ទៅទីក្រុងម៉ុងប៉េលីយេ នៅទីក្រុងម៉ុងប៉េលីយេនេះហើយដែលខ្លួនបានសិក្សាជំនាញផ្នែកច្បាប់ និងពាណិជ្ជកម្ម ស្របពេលជាមួយគ្នានោះជនជាប់ចោទរូបនេះក៏បានចូលរួមប្រជុំជាមួយនឹងរង្វង់ម៉ាកស៊ីសនៅទីនោះ ។ ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ថា បីឆ្នាំក្រោយមកខ្លួនក៏បានផ្លាស់មកទីក្រុងប៉ារីសវិញ ដើម្បីរៀបចំធ្វើនិក្ខេបបទថ្នាក់បណ្ឌិតរបស់



ខ្លួនខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ នៅទីនោះហើយដែលខ្លួនបានចូលរួមប្រជុំជាទៀងទាត់ជាមួយនឹងវង់ម៉ាកស៊ីស ។ ក្រោយការត្រឡប់ចូលប្រទេសវិញរបស់ អៀង សារី ជនជាប់ចោទ ខៀវ សំផន បានទទួលភារកិច្ចបន្តពី អៀង សារី ក្នុងការជួយបំផុសចលនាស្នេហាជាតិនៅក្នុងរង្វង់ពួកម៉ាកស៊ីស នៅទីក្រុងប៉ារីសនោះ ។

ជនជាប់ចោទ ខៀវ សំផន បានអះអាងថា នៅពេលដែលខ្លួនមើលឃើញសម្តេច សីហនុ បានបដិសេធការប្រកាសជាឯកតោភាគីពីសំណាក់អង្គការសេអាតូ ដាក់ប្រទេសកម្ពុជាឲ្យស្ថិតនៅក្រោមម្លប់របស់អង្គការនេះ ហើយព្យាយាមយ៉ាងអង់អាចក្នុងការទាក់ទងផ្នែកការទូតជាមួយក្រុមប្រទេសដែលប្រកាន់យករបបសង្គមនិយម ធ្វើឲ្យខ្លួនសង្ឃឹមថា កម្ពុជានឹងអាចធ្វើកំណែទម្រង់សេដ្ឋកិច្ច និងសង្គមរបស់ខ្លួនដើម្បីទទួលប្រព័ន្ធសេដ្ឋកិច្ចឯករាជ្យ



ខៀវ សំផន

មួយរបស់ខ្លួន ដូចដែលប្រទេសជប៉ុនធ្លាប់បានធ្វើ ។ ដូច្នេះហើយ ទើបខ្លួនសម្រេចជ្រើសរើសយកប្រធានបទ "បញ្ហានៃឧស្សាហូបនីយកម្មកម្ពុជា" ដើម្បីធ្វើជានិក្ខេបបទរបស់ខ្លួន ដោយជឿថាឲ្យតែមានវិធានការសមស្រប នាយទុនជាតិមួយនឹងអាចរីកលូតលាស់បាន ។ នៅក្នុងនិក្ខេបបទនោះ ជនជាប់ចោទ ខៀវ សំផន បានចោទជាសំណួរសំខាន់មួយថា "ហេតុអ្វីបានជាហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនៅពេលនោះមិនអាចឲ្យមានការអភិវឌ្ឍន៍ប្រទេសកម្ពុជា?" នោះគឺដោយសារតែទំនិញឧស្សាហកម្មរបស់បារាំងមកប្រកួតប្រជែងជាមួយសិប្បកម្មខ្មែរ ដែលជាហេតុធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាក្លាយជាសេដ្ឋកិច្ចកសិកម្មអន់ថយទៅវិញ ។ នៅក្នុងនោះជនជាប់ចោទ ខៀវ សំផន បានលើកឡើងនូវទ្រឹស្តីរបស់សេដ្ឋវិទូជនជាតិ អេកូស ម្នាក់ឈ្មោះ អាដាម ស្មីត ដែលថារដ្ឋត្រូវតែកាន់កាប់ពាណិជ្ជកម្មក្រៅប្រទេស ដើម្បីធ្វើជាឧបករណ៍សម្រាប់ជួយដល់ការរីកលូតលាស់នៃសិប្បកម្ម ហើយតម្រង់កម្លាំងការងារទៅខាងពាណិជ្ជកម្ម ។ ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ថា នៅក្នុងនិក្ខេបបទរបស់ខ្លួន ខ្លួនមិនដែលគាំទ្រឲ្យមានការលុបបំបាត់ការប្រើប្រាស់លុយ លុបបំបាត់កម្មសិទ្ធិឯកជន ឬលុបបំបាត់ទីក្រុងនោះទេ ។ នៅអំឡុងពេលរស់នៅប្រទេសបារាំង ខៀវ សំផន បានចូលរួមបក្សកុម្មុយនីស្តបារាំងនៅឆ្នាំ១៩៥៥ និងចូលរួមនៅក្នុងការធ្វើបាតុកម្មប្រឆាំងនឹងសង្រ្គាមនៅវៀតណាម និងសង្រ្គាមនៅប្រទេសអាល់ហ្សេរី ដោយគិតថា ការតស៊ូរបស់ប្រជាជនដែលរស់នៅក្រោមនឹមអាណានិគមនិយម និងធ្វើឲ្យអាណានិគមនិយមចុះខ្សោយ ដែលអាចធ្វើឲ្យប្រទេសកម្ពុជាឆាប់ទទួលបានឯករាជ្យឆាប់រហ័ស ។ ជនជាប់ចោទ ខៀវ សំផន បានព្យាយាមអះអាងថា ការទទួលបានឯករាជ្យរបស់ប្រទេសកម្ពុជាពីសំណាក់ប្រទេសបារាំង មិនមែនដោយសារព្រះរាជបូជនីយកិច្ចរបស់ព្រះបាទសម្តេច នរោត្តម សីហនុ ទេ ប៉ុន្តែគឺដោយសារតែការតស៊ូរបស់ប្រជាជនវៀតណាម និងជ័យជម្នះរបស់វៀតណាមនៅសមរភូមិ ឌៀនបៀនភូ ទៅវិញទេ ។ ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា សាខាបក្សកុម្មុយនីស្តរបស់ខ្លួនគឺខុសគ្នាពីសាខាបក្សកុម្មុយនីស្តរបស់ ប៉ុល ពត អៀង សារី និង រដ្ឋ សាមឿន ដែលជាសាខាបក្សកម្មករ រីឯសាខាបក្សរបស់ខ្លួននៅតាមមហាវិទ្យាល័យ ។ ក្រោយមកខ្លួនក៏បានសម្រេចចិត្តឈប់ចូលរួមប្រជុំជាមួយនឹងបក្សកុម្មុយនីស្តនោះ ដោយសារតែគេលើកឡើងតែពីបញ្ហារបស់បារាំង ។ ក្រោយពេលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៨ ជន ជាប់ចោទ ខៀវ សំផន បានអះអាងថា ខ្លួនមិនដែលមានទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តកម្ពុជាឡើយ ព្រោះការទាក់ទងជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជានោះអាចនឹងធ្វើឲ្យខ្លួនមានគ្រោះថ្នាក់ ដោយសារមានគិញតាមដានខ្លួនជានិច្ច សូម្បីនៅពេលដែលខ្លួនធ្វើជាតំណាងរាស្ត្រ និងជារដ្ឋលេខាក្រសួងពាណិជ្ជកម្ម ។ ទាក់ទងនឹងការកថាខណ្ឌ១១២៧ នៃដីកាដំណោះស្រាយដែលលើកឡើងថា កាសែតដែលជនជាប់ចោទ ខៀវ សំផន បានចេញផ្សាយជាកាសែតដែលឧបត្ថមដោយពួកកុម្មុយនីស្តនោះ ត្រូវបានជនជាប់ចោទ ខៀវ សំផន អត្ថាធិប្បាយថាអ្នកដែលឧបត្ថមកាសែតរបស់ខ្លួនភាគច្រើនមិនមែនជាអ្នកកុម្មុយនីស្តទេ ទោះបីជាមានអ្នកកុម្មុយនីស្តខ្លះក៏ដោយ ព្រោះពួកគេជាតំណាងរាស្ត្រនៃសភាជាតិដូចជា ហ៊ូ យន់ ហ៊ូ នឹម អ៊ុច វ៉ែន និង សូ នៃ ជាដើម ។ ជនជាប់ចោទ ខៀវ សំផន បានរំឭកថា នៅពេលត្រឡប់មកប្រទេសកម្ពុជាវិញ ហ៊ូ នឹម និង ហ៊ូ យន់ ដែលជាមិត្តភក្តិរៀនជាមួយគ្នានៅឯប្រទេសបារាំង បានស្នើឲ្យខ្លួនចេញកាសែតមួយដើម្បីបង្ហាញពីសំឡេងរបស់យុវជន កាសែតនោះបោះពុម្ពជាភាសាបារាំង គឺកាសែត អុបសេវ៉ាទ័រ (L'Observateur) ។ កាសែតនេះចេញផ្សាយក្នុងគោលបំណងគាំទ្រដល់ចលនាអព្យាក្រឹត្យរបស់សម្តេច សីហនុ និងសង្ឃឹមថាអាចធ្វើឲ្យមានការចុះថយគម្លាតជីវភាពប្រជាជនបានខ្លះព្រោះកាសែតនេះបោះពុម្ពឡើងសំដៅសម្រាប់អ្នកដឹកនាំប្រទេសអាន ដោយសារអ្នកដឹកនាំនៅពេលនោះចូលចិត្តអានកាសែតជាភាសាបារាំង រីឯប្រជាជនសាមញ្ញមិនសូវមានអ្នកអានកាសែតនោះឡើយ ។ ជនជាប់ចោទ ខៀវ សំផន បានបង្ហាញពីការតិទៀនទៅដល់សម្តេច នរោត្តម សីហនុ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន នៅពេលដែលជនជាប់ចោទរូបនេះនិយាយដល់ការចោទប្រកាន់កាសែតរបស់ខ្លួនថាជា កាសែតក្រហម ឬកាសែតកុម្មុយនីស្ត ។ ខៀវ សំផន អះអាងថា ពាក្យថា កាសែតក្រហមនេះគឺចេញមកអំពីសម្តេច សីហនុ ចាប់ផ្តើមមានការភ័យព្រួយពីគំនិតឯករាជ្យរបស់ខ្លួន ។ មានថ្ងៃមួយនោះ ខ្លួនត្រូវបានកោះហៅទៅសួរចម្លើយនៅក្រសួងប៉ូលីសពិសេស នៅពេលដែល

កាសែតចាប់ផ្តើមដំណើរការ ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឈ្មោះ គូ រុណ បានសាកសួរខ្លួនដោយផ្ទាល់ ។ ខៀវ សំផន បានបញ្ជាក់ថា នៅក្រោយពេលដែលខ្លួនត្រូវបានគេដោះលែងឲ្យត្រឡប់ទៅវិញ ខ្លួនបានសរសេររាល់សំណួរទាំងឡាយ ដែល គូ រុណ សួរមកខ្លួន និង ចម្លើយទាំងឡាយដែលខ្លួនបានឆ្លើយទាំងអស់ដើម្បីទុកចុះផ្សាយនៅក្នុងអត្ថបទកាសែតរបស់ខ្លួននៅពេលដែលខ្លួនត្រឡប់ទៅវិញ ។ ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ថា ខ្លួនចង់បង្ហាញទៅតុលាការនូវសំណួរចំនួនពីរដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឈ្មោះ គូ រុណ នោះបានសួរមកកាន់ខ្លួននៅអំឡុងពេលនៃការសាកសួរនោះ ។ ជនជាប់ចោទ ខៀវ សំផន បានរៀបរាប់ថា សំណួរទីមួយដែល គូ រុណ បានសួរខ្លួនគឺថា «តើហេតុអ្វីក៏អ្នកឯងស្អប់ព្រះបរមរាជវាំងខ្លាំងម្ល៉េះ?» រីឯសំណួរទី២គឺថា «ហេតុអ្វីក៏អ្នកឯងមិនព្រមធ្វើការរាជការក្រោយពេលរៀនចប់ បែរជាធ្វើកាសែតទៅវិញ? តើអ្នកឯងចង់ធ្វើស្តេចឬ? បើចង់ធ្វើស្តេចប្រយ័ត្នដេកនៅក្នុងម្ជុងឈើ។ ជនជាប់ចោទ ខៀវ សំផន បានបន្តទៀតថា រយៈពេលបីខែក្រោយពីការសួរចម្លើយរបស់លោករដ្ឋមន្ត្រី គូ រុណ មានមនុស្សមួយក្រុមបានចាប់វាយធ្វើបាប និងចាប់សម្រាតខោអាវរបស់ខ្លួននៅកណ្តាលផ្លូវ ហើយកាសែតរបស់ខ្លួនក៏ត្រូវបានគេបញ្ជាឲ្យបិទ ។ ក្រោយមកជនជាប់ចោទ ខៀវ សំផន ក៏ត្រូវបានគេចាប់ខ្លួនដាក់ពន្ធនាគាររយៈពេលមួយខែដោយគ្មានដីកាចាប់ខ្លួនពីតុលាការ ។ ជនជាប់ចោទ ខៀវ សំផន បានបន្តថា នៅឆ្នាំ១៩៦២ ខ្លួនត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រនៃរបបសង្គមរាស្ត្រនិយម បន្ទាប់មកត្រូវបានចាត់តាំងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មដោយភ្លាមៗ ដែលការតែងតាំងជារដ្ឋលេខាធិការនេះត្រូវបានជនជាប់ចោទរូបនេះអះអាងថាគ្រាន់តែជាការទិញទឹកចិត្តរបស់ខ្លួនពីសំណាក់សម្តេច សីហនុ តែប៉ុណ្ណោះ និងបញ្ជាក់ថាខ្លួននៅតែរក្សាគំនិតធ្វើកំណែទម្រង់សេដ្ឋកិច្ចរបស់ខ្លួនជានិច្ច ទោះបីជាត្រូវទទួលតំណែងនេះក៏ដោយ ។ នៅអំឡុងពេលដែលខ្លួនមានតំណែងជារដ្ឋលេខាធិការ ជនជាប់ចោទ ខៀវ សំផន បានចាប់ផ្តើមមានឱកាសក្នុងការទាក់ទងជាមួយនឹងមន្ត្រីដែលមានបទពិសោធច្រើនដូចជា លោក សឺន សាន លោក មាត់ គង់ និង លោក ប៉ែន នុត ដើម្បីស្តាប់សង់ពីលទ្ធភាពក្នុងការធ្វើកំណែទម្រង់សេដ្ឋកិច្ច ។ ខៀវ សំផន បានជម្រាបទៅអង្គជំនុំជម្រះថា ខ្លួនធ្លាប់បានពិភាក្សាជាមួយនឹង លោក សឺន សាន ដែលមានតួនាទីជាទេសាភិបាលធនាគារជាតិនៅពេលនោះអំពីបញ្ហាការលួចបន្លំរូបិយវត្ថុបរទេសដើម្បីលក់នៅក្នុងទីផ្សារងងឹតដែលបង្កឲ្យមានការព្រួយបារម្ភចំពោះសេដ្ឋកិច្ចជាតិ ដោយសារតែនៅក្នុងទីផ្សារដាក់ស្តែង ១ដុល្លារសហរដ្ឋអាមេរិក គឺប្តូរបានត្រឹមតែ ៣០ រៀលប៉ុណ្ណោះ ប៉ុន្តែ១ដុល្លារដែលគេអាចលក់បាន២០០ រៀលនៅក្នុងទីផ្សារងងឹត ។ គម្រោងនៃការធ្វើកំណែទម្រង់ត្រូវបានទទួលយកដោយលោក សឺន សាន បន្ទាប់មកលោក សឺន សានការបានយកគម្រោងនោះទៅថ្វាយសម្តេចព្រះនរោត្តមសីហនុដើម្បីសម្រេចពីបញ្ហានេះ ។ ខៀវ សំផន បានបន្ថែមថា

> *«សម្តេច សីហនុ ពេលនោះក៏លោកព្រួយបារម្ភពីការដែលកម្ពុជាកាន់តែរណបជំនួយអាមេរិកកាន់តែខ្លាំងឡើងៗ ឯអាមេរិកចេះតែគម្រាមកាត់ជំនួយដូច្នេះជំនួយអាមេរិកប្រៀបបានទៅនឹងកាំបិតភ្ជង់កម្ពុជាជាប់ ។ គម្រោងរបស់ខ្ញុំនេះ ក៏ត្រូវបានសម្តេចសព្វព្រះទ័យយ៉ាងឆាប់រហ័ស ។»*

ជនជាប់ចោទ ខៀវ សំផន បានគូសបញ្ជាក់ដោយអស់សំណើចថា បន្ទាប់ពីការទទួលយកគម្រោងធ្វើកំណែទម្រង់ពីសំណាក់សម្តេចនរោត្តម សីហនុ ហើយ ខ្លួនត្រូវបានធ្លាក់ពីតួនាទីជារដ្ឋលេខាក្រសួងពាណិជ្ជកម្មដោយសារតែបញ្ហាសាច់គោឡើងថ្លៃ ។ ជនជាប់ចោទ ខៀវ សំផន បានបន្តថា ការធ្លាក់ពីតំណែងនេះគឺដោយសារតែសម្តេច សីហនុ ព្រួយបារម្ភខ្លាចខ្លួនមានប្រជាប្រិយភាពជាងព្រះអង្គ ដោយសារគម្រោងធ្វើកំណែទម្រង់នោះគឺខ្លួនជាអ្នកបង្កើតឡើង ។

នៅអំឡុងពេលដែលជនជាប់ចោទ ខៀវ សំផន កំពុងតែរៀបរាប់អំពីសកម្មភាពរបស់ខ្លួននៅអំឡុងពេលនៃរបបសង្គមរាស្ត្រនិយមរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុទាំងចៅក្រមទាំងគ្រប់ភាគី និងអ្នកចូលរួមទាំងអស់នៅក្នុងបន្ទប់សវនាការបានស្ថិតនៅក្នុងភាពស្ងាត់ស្ងៀម ដោយផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើពាក្យសម្តីដែល ខៀវ សំផន លើកឡើង ។

### មូលហេតុដែលនាំរត់ចូលព្រៃនៅឆ្នាំ១៩៦៧

ជនជាប់ចោទ ខៀវ សំផន បានចាប់ផ្តើមបន្តរៀបរាប់អំពី

មូលហេតុដែលនាំឲ្យខ្លួនរត់ចូលព្រៃនៅឆ្នាំ១៩៦៧ ដែលមានលើកឡើងនៅក្នុងដីកាដំណោះស្រាយត្រង់កថាខណ្ឌ១១២៨ និងកថាខណ្ឌ១៦០០ ។ ខៀវ សំផន បានអះអាងនៅក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួនថាៈ

«ដែលនាំឲ្យខ្ញុំរត់ចូលព្រៃនេះ គឺជាការបង្ខំចិត្ត ។ ចិត្តខ្ញុំ ខ្ញុំចង់បន្តធ្វើការងាររបស់ខ្ញុំជាតំណាងរាស្ត្រ ប៉ុន្តែខ្ញុំគ្មានឲ្យផ្លូវឯណាផ្សេងទៀតទេក្រៅពីរត់ចេញពីភ្នំពេញ ពីព្រោះសន្តិសុខរបស់ខ្ញុំលែងធានាបានទៀតហើយ ។ ខ្ញុំត្រូវគេគំរាមចាប់ ហើយនាំខ្លួនទៅតុលាការសឹក ក្រោមលេសថាខ្ញុំជាមេនាំឲ្យកសិករបះបោរនៅសំឡូត ការពិតខ្ញុំទាំងស្គាល់ថាសំឡូតនៅឯណាផង ។ ហើយខ្ញុំក៏មិនជឿថា កសិករនាំគ្នាបះបោរដោយសារតែកាសែតខ្ញុំញុះញង់នោះឡើយ ព្រោះគេមិនអានអក្សរបារាំងទេ ។»

ជនជាប់ចោទ ខៀវ សំផន បានបន្តទៀតថា ចាប់តាំងពីឆ្នាំ១៩៦៦ សម្ដេច នរោត្តម សីហនុ ត្រូវបានកម្លាំងខាងស្ដាំរបស់លោក លន់ នល់ ដែលស្និទ្ធជាមួយនឹងអាមេរិកហ៊ុំព័ទ្ធព្រះអង្គជិត ដែលជាហេតុធ្វើឲ្យទ្រង់យល់ថាការភ្ជាប់ទំនាក់ទំនងជាមួយនឹងសហរដ្ឋអាមេរិកក្លាយជារឿងមួយសំខាន់ ហើយងាកមកវាយប្រហារ និងគំរាមចាប់ចងក្រុមដែលនិយមទៅខាងឆ្វេង ដែលធ្វើឲ្យខ្លួនត្រូវបង្ខំចិត្តរត់ចេញពីទីក្រុងភ្នំពេញហើយក្លាយទៅជារបស់ដែលមានតម្លៃសម្រាប់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ ។

## ក្រោយការផ្ទុះរដ្ឋប្រហារឆ្នាំ១៩៧០

ទាក់ទងនឹងការផ្ទុះរដ្ឋប្រហារនៅក្រោយឆ្នាំ១៩៧០នៅត្រង់កថាខណ្ឌ២៥ និង១១២៩នៃដីកា ដំណោះស្រាយ ជនជាប់ចោទ ខៀវ សំផន បានអះអាងថា នៅក្រោយរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្ដេច សីហនុ នៅក្នុងឆ្នាំ១៩៧០ សម្ដេច សីហនុ បានអំពាវអំនាវឲ្យបង្កើតរដ្ឋាភិបាលរួបរួមជាតិមួយនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ នៅទីក្រុងប៉េកាំង ដោយមានការជួយសម្រួលពីសំណាក់លោក ជូអេនឡាយ ។ ប៉ុន្តែជាប់ចោទរូបនេះបានបញ្ជាក់ថា ការពិតសេចក្ដីអំពាវនាវនេះមិនមែនជាស្នាព្រះហស្តរបស់សម្ដេចទាំងស្រុងទេ ពីព្រោះសេចក្ដីអំពាវនាវនេះត្រូវបានលោក ជូអេនឡាយ យកទៅបង្ហាញ សាឡុត ស ហើយសាឡុត ស បានលុបចោលចំណុចខ្លះដែលទាក់ទងនឹងសង្គមនិយម ។ ខៀវ សំផន បានបន្តថា នៅពេលនោះ សាឡុត ស មិនបានទៅជួបនឹងសម្ដេច សីហនុ ដោយផ្ទាល់ទៅតាមការស្នើរបស់ លោក ជូអេនឡាយ ឡើយ តែបែជាសរសេរសំបុត្រមួយច្បាប់ផ្ញើទៅសម្ដេចសីហនុ ដោយដាក់ឈ្មោះខ្លួន ហូ យន់ និងហ៊ូ នឹម ទៅវិញ ហើយថាសំបុត្រនេះផ្ញើចេញពីមូលដ្ឋានតស៊ូនៅក្នុងប្រទេស ។ ជនជាប់ចោទ ខៀវ សំផន បានអះអាងថា ខ្លួនបានដឹងការអំពាវនាវនេះនៅពេលបន្ទាប់ក្រោយពីមានការផ្សព្វផ្សាយតាមរយៈវិទ្យុប៉ុណ្ណោះ ។ ជនជាប់ចោទ ខៀវ សំផន បានស្នើសុំទៅអង្គជំនុំជម្រះធ្វើការកត់សម្គាល់នូវចំណុចសំខាន់មួយទៀតថា មូលហេតុដែល សាឡុត ស មិនព្រមជួបជាមួយនឹងសម្ដេច សីហនុ គឺ ដោយសារតែ សាឡុត ស គឺជាលេខាបក្សកុម្មុយនីស្តកម្ពុជា ដែលជាបក្សរបស់កសិករ ពលករកម្ពុជាតស៊ូវាយរំលំរបបសក្តិភូមិ ។ ហេតុនេះតម្រូវឲ្យខ្លួនត្រូវធ្វើជាស្ពានរវាងបក្សកុម្មុនីស្តកម្ពុជា និងសម្ដេច សីហនុ ដើម្បីធ្វើឲ្យមានចលនាបង្រួបបង្រួមជាតិ ដោយមិនប្រកាន់ពណ៌សម្បុរនយោបាយ ។ នៅពេលមកដល់ត្រឹមចំណុចនេះ ជនជាប់ចោទ ខៀវ សំផន បានចោទសួរថា «តើនេះជាឧក្រិដ្ឋកម្មឬ?» និងបានឆ្លើយខ្លួនឯងភ្លាមៗថា «មិនមែនទេ គឺច្បាស់ជាមិនមែនទេ» ។ ខៀវ សំផន បានបន្ថែមថា ខ្លួនមិនដឹងខ្លួនថា ប៉ុល ពត បានតែងតាំងខ្លួនជាឧបនាយករដ្ឋមន្ត្រីនៅពេលនោះឡើយ ដោយនិយាយក្នុងទឹកមុខម៉ឺងម៉ាត់ និងសម្ដីមួយៗនិងខ្លាំងៗថាៈ

«ច្បាស់ហើយ គឺ ប៉ុល ពត ដែលបានចាត់តាំងខ្ញុំឲ្យទទួលមុខតំណែងដែលខ្ញុំមិនបានដឹងសោះ នោះជាឧបនាយកខ្យល់រដ្ឋមន្ត្រីការពារប្រទេសខ្យល់ អគ្គបញ្ជាការខ្យល់ ។ល ។ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាឯណោះទេ ដែលជាអ្នកដឹកនាំការតស៊ូតាំងពីសង្គ្រាមឈ្លបនៅក្នុងឆ្នាំ១៩៦៨-៦៩ មករហូតក្នុងនាមជាកងពលក្នុងសង្គ្រាមពីឆ្នាំ១៩៧០ទៅ៧៥ ។ បើដូច្នោះ គេនៅអះអាងថាខ្ញុំជាអ្នកមានអំណាចធំសម្បើមណាស់ យ៉ាងនេះយ៉ាងនោះបានទៀតទេ ។ អត់ទេ វាទៅមិនរួចទេ ។ បើឧបនាយក

*ខ្យល់ រដ្ឋមន្ត្រីការពារប្រទេសខ្យល់ អគ្គបញ្ជាការទ័ពខ្យល់ ។ ការពិតខ្ញុំគ្មានឥទ្ធិពលអ្វី តែបន្តិចក៏គ្មានដែរទៅលើកងទ័ព សូម្បីតែអង្គភាពតូចមួយក៏គ្មាននៅក្រោមបង្គាប់របស់ខ្ញុំដែរ ។»*

ជនជាប់ចោទ ខៀវ សំផន លើកឡើងថា ខ្លួនមានអារម្មណ៍ប្រហាក់ប្រហែលនឹងជនជាប់ចោទ នួន ជា ដែលបាននិយាយកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ដែរ ព្រោះខ្លួនមិនអាចឈរមើលប្រទេសកម្ពុជាដែលទើបរួចផុតពីអាណានិគមបារាំង និងអាចរំដោះផុតពីកណ្តាប់ដៃរបស់អាមេរិក ហើយបែរជាធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនីស្តវៀតណាមឡើយ ។

### តួនាទីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា

ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ទៅអង្គជំនុំជម្រះថា ខ្លួនបានចូលរួមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦៩ នៅលើភ្នំឱរ៉ាល់ ជាមួយនឹង ហូ យន់ ហ៊ូ នឹម និង ប៉ុក ដឹកុមារ ដែលត្រូវបានដាក់បញ្ចូលដោយ តាម៉ុក ដែលជាអ្នកជំនួសមុខឲ្យបក្សកុម្មុនីស្តកម្ពុជា ។ ការចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាគឺតម្រូវឲ្យមានសកម្មភាពប្រយុទ្ធ ហើយត្រូវឆ្លងកាត់ការកសាងលត់ដំសាកល្បងក្នុងការតស៊ូបដិវត្តន៍ ។ មួយទៀតត្រូវមានវណ្ណៈភាពល្អ ដែលវណ្ណៈភាពល្អនោះត្រូវតែជាកូនកសិករក្រីក្រ ។ ដូច្នេះខៀវ សំផន បានបដិសេធថា ខ្លួនមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីបំពេញលក្ខខណ្ឌទាំងនេះឡើយ ។ម្យ៉ាងទៀត ខ្លួនមិនមែនជាកូនកសិករក្រីក្រ ព្រោះខ្លួនជាអ្នកដែលបានរៀនសូត្រខ្ពង់ខ្ពស់នៅឯបរទេស និងមិនដែលបានចូលរួមតស៊ូបដិវត្តទេ ដោយសារការរត់ចូលក្នុងព្រៃនោះគឺធ្វើឡើង ដោយបង្ខំចិត្ត ។

ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ថា ការដែលខ្លួនបានចូលជាសមាជិកត្រៀមនៃគណៈមជ្ឈិមនៅក្នុងឆ្នាំ១៩៧១នោះ គឺដោយសារតែខ្លួនមាននាទីជាស្ពានភ្ជាប់ការទាក់ទងរវាងបក្សកុម្មុនីស្តកម្ពុជា និងសម្តេចសីហនុ ។ តាមការពិត ប៉ុល ពត នៅតែចាត់ទុកខ្លួនថាជាមនុស្សរបស់រណសិរ្ស ហើយគេមិនដែលចាត់ទុកខ្លួនថាជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានោះទេ ។ ខៀវ សំផន បញ្ជាក់ទៅអង្គជំនុំជម្រះថា សមាជិកបម្រុងនៃគណៈមជ្ឈិម គឺគ្មានសិទ្ធិអំណាចក្នុងការសម្រេចអ្វីទាំងអស់ ។ ដោយលើកជាឧទាហរណ៍



ថាសមាជិកមជ្ឈិមផ្សេងទៀតគេសុទ្ធតែមានអំណាចគ្រប់គ្រងភូមិភាគ ប៉ុន្តែខ្លួនជាសមាជិកមជ្ឈិមនឹងគេដែរ គឺមាននាទីជាត្រឹមតែជាអ្នកសរសេររបាយការណ៍ជាទៀតទាត់ជូនទៅសម្ដេច សីហនុ ទៅវិញ ។ ខៀវ សំផន បានធ្វើការប្រៀបធៀបខ្លួនទៅនឹងឥស្សរជននៅវៀតណាមខាងត្បូង ដែលក្រោយពីវៀតណាមខាងត្បូងត្រូវបានរំដោះពួកអ្នកទាំងនោះបានបាត់ឈ្មោះគ្មានតំណែងអ្វីឡើយ ។

ជនជាប់ចោទជាប់ចោទ ខៀវ សំផន ខិតខំបង្ហាញទៅអ្នកចូលរួម និងប្រជាជនកម្ពុជាថា មូលហេតុដែលខ្លួនមិនមានអំណាចសម្រេចអ្វីទាំងអស់នៅពេលដែលខ្លួនជាមេដឹកនាំជាន់ខ្ពស់នោះ គឺដោយសារតែ ប៉ុល ពត និងបក្សកុម្មុយនីស្តកម្ពុជាតែងតែនៅចាត់ទុកខ្លួនថាជាពួកបញ្ញាជន ។

មុននឹងបញ្ចប់សេចក្ដីថ្លែងការណ៍របស់ខ្លួន ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់បន្ថែម ដោយលើកឡើងនូវសំណួរមួយថា តើហេតុអ្វីបានជាប្រជាជនកម្ពុជាភាគច្រើនលើសលប់ផ្ដល់ការគាំទ្ររបស់គេទៅដល់ចលនាតស៊ូក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា? សំណួរនេះត្រូវបានជាប់ចោទ ខៀវ សំផន បកស្រាយថា ៖

> “តាមខ្ញុំយល់ គឺដោយសារគេអស់សង្ឃឹមខ្លាំងនឹងរបប លន់ នល់ ដែលពុករលួយដល់ឆ្អឹង ហើយជាបរិវារដាច់ថ្លៃរបស់សហរដ្ឋអាមេរិក តែបើមើលមកចលនាតស៊ូវិញ គេឃើញមនុស្សដែលគេស្គាល់ច្បាស់ថាជាមនុស្សស្អាតស្អំ ហើយការពារឯករាជ្យនិងអធិបតេយ្យភាពជាតិដាច់ខាត គេនឿយណាយដោយឃើញតែអំពើពាលាអាវ៉ាសែ អំពើខ្ក្រិដ្ឋ និងអនាធិបតេយ្យនៅក្នុងរបប លន់ នល់ ឯខាងការតស៊ូគេលឺថា វិន័យតឹងរឹងណាស់ ប៉ុន្តែគេត្រៀមខ្លួននឹងទទួលគោរពតាម ពីព្រោះគេស្រេកឃ្លានចង់បាននូវសង្គមមួយដែលប្រកបទៅដោយគុណធម៌ និងសីលធម៌ ។”

## ២) ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី

នៅអំឡុងពេលសវនាការលើអង្គសេចក្ដីទាក់ទងនឹងការសួរដេញដោលភស្ដុតាង អង្គជំនុំជម្រះសាលាដំបូងបានកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបដើម្បីផ្ដល់សក្ខីកម្មនៅក្នុងសវនាការ ។ ដើមបណ្ដឹងរដ្ឋប្បវេណីទីមួយគឺលោក ក្លាន វ៉ិត រស់នៅភូមិអ៊ិន ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនគិរី ជាជនជាតិកាចក់ និងទីពីរគឺលោក រម៉ាម យុន ហៅ ខាំភី មានអាយុ៧០ឆ្នាំ រស់នៅភូមិកាចូត ស្រុកអណ្ដូងមាស ខេត្តរតនគិរី ។ នាក់ទាំងពីររូប គឺជាដើមបណ្ដឹងរដ្ឋប្បវេណីដំបូងបង្អស់នៅក្នុងសំណុំរឿង០០២ ដែលត្រូវបានអង្គជំនុំជម្រះកោះហៅឲ្យមកផ្ដល់សក្ខីកម្មនៅក្នុងអង្គសវនាការ ។

នៅអំឡុងពេលនៃការសួរដេញដោលនៅក្នុងសវនាការ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីររូបហាក់បីដូចជាមានការលំបាកក្នុងការស្វែងយល់ពីសំណួររបស់ភាគីដែលចោទសួរមកលើខ្លួន ព្រោះភាគច្រើននៃចម្លើយរបស់អ្នកទាំងពីរមិនបានឆ្លើយតបទៅនឹងសំណួរដែលត្រូវបានចោទសួរមកលើខ្លួនឡើយ ។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរត្រូវបានអង្គជំនុំជម្រះបន្ទាប់ឲ្យមានអ្នកជំនួយម្នាក់ដើម្បីជួយសម្របសម្រួល និងជួយបកប្រែរាល់ពាក្យពេចន៍ និងឃ្លាទាំងឡាយណាដែលមានភាពមិនច្បាស់លាស់ ដោយហេតុថាដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីររូប ជាជនជាតិភាគតិច ហើយមិនបានប្រើប្រាស់ភាសាខ្មែរជាភាសាដើមរបស់ខ្លួន ។ ម្យ៉ាងវិញទៀត បញ្ហាវ័យចាស់ជរា និងសុខភាពរបស់អ្នកទាំងពីរ ក៏ត្រូវបានកត់សម្គាល់ដោយអង្គជំនុំជម្រះ ។ លោកចៅក្រម និល ណុន ដែលជាប្រធាននៃអង្គជំនុំជម្រះ បានចាប់ផ្ដើមសាកសួរជាដំបូងទាក់ទងនឹងប្រវត្តិរូបសង្ខេបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មុននឹងប្រគល់វេទិកាទៅឲ្យភាគីទាំងអស់ដើម្បីបន្តដំណើរការនីតិវិធីសាកសួរដើមបណ្ដឹងរដ្ឋប្បវេណី ។ បន្ទាប់ពីការសួរសំណួររបស់លោកប្រធានអង្គជំនុំជម្រះ និល ណុន មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានប្រគល់វេទិកាឲ្យធ្វើការសួរកូនក្ដីរបស់ខ្លួន និងបន្ទាប់មកជាភារកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ។

### ១) ការធ្វើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្លាន វ៉ិត

ឆ្លើយតបនឹងសំណួររបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងសហព្រះរាជអន្តរជាតិពាក់ពន្ធ័នឹងការចូលរួមចលនាបដិវត្តន៍ លោក ក្លាន វ៉ិត មានប្រសាសន៍ថា មុន

ពេលដែលខ្លួនចូលរួមធ្វើបដិវត្តន៍ដំបូង មានគេមកប្រាប់ថា បើមិនចូលបដិវត្តន៍ទេនោះនឹងត្រូវស្លាប់ ពីព្រោះខ្មាំងសក្តិភូមិនឹងធ្វើបាប ។ នៅពេលឮដូចនេះ ខ្លួនបានសម្រេចចូលរួមធ្វើបដិវត្តន៍ជាមួយនឹងគេ ។ ចាប់តាំងពីពេលនោះមកខ្លួនត្រូវបានឈ្មោះ វ៉ាង និង ស៊ី ចាត់តាំងឲ្យខ្លួនធ្វើជានិរសាដើម្បីរត់សំបុត្រឲ្យកម្មាភិបាល និងបន្ទាប់មកធ្វើប្រធានភូមិដើម្បីធ្វើការអប់រំប្រជាជន និងផ្គត់ផ្គង់ផ្នែកសេដ្ឋកិច្ចដល់បដិវត្តន៍ ។ លោក ក្វាន វ៉ុត បានបញ្ជាក់ថា ខ្លួនធ្លាប់បានជួបជនជាប់ចោទ អៀង សារី ដែលពេលនោះបានឃោសនាអប់រំឲ្យខិតខំធ្វើការដើម្បីបម្រើបដិវត្តន៍ ។ លើសពីនោះទៀត អៀង សារី បានបង្រៀនដល់មេភូមិ មេឃុំ កុំឲ្យហៅវៀតណាមថាយួន ព្រោះវៀតណាម ឡាវ និងកម្ពុជាគឺជាបងប្អូនជីដូនមួយ ។ បន្ថែមលើនេះលោក អៀង សារី ថែមទាំងបានប្រកាសប្រាប់ថ្នាក់ស្រុក ថ្នាក់ឃុំ ឲ្យយល់ពីអ្វីជាខ្មាំង និងអ្វីជាសត្រូវទៀតផង ។ លោក វ៉ុត បានអះអាងថា នៅពេលនោះ ជនជាប់ចោទ អៀង សារី នួន ជា ខៀវ សំផន និង ប៉ុល ពត គឺមានតួនាទីជាគណៈភូមិភាគឦសាន្ត ។ លោក ក្វាន វ៉ុត បានធ្វើការបញ្ជាក់ជាចុងក្រោយថា មូលហេតុដែលអង្គការជ្រើសរើសយកជនជាតិភាគតិចឲ្យចូលធ្វើបដិវត្តន៍ ដោយសារជនជាតិភាគតិចគឺជាមនុស្សល្ងង់មិនដឹងអ្វីជាខ្មាំង អ្វីជាបដិវត្តន៍នោះឡើយ ។

### ២) ការធ្វើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន

លោក រម៉ាម យុន គឺជាដើមបណ្តឹងរដ្ឋប្បវេណីទីពីរ ដែលបានធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងសហព្រះរាជ អាជ្ញាអន្តរជាតិ លោក រម៉ាម យុន មានប្រសាសន៍ថា ខ្លួនត្រូវបានគេឃោសនាឲ្យចូលរួមធ្វើបដិវត្តន៍ដើម្បីរំដោះជាតិ និងបម្រើប្រទេសឲ្យមានការរីកចម្រើន ប៉ុន្តែក្រោយមកអ្វីៗមិនដូចការគ្រោងទុកនោះទេ ។ លោក យុន បានបញ្ជាក់ថា ការចូលបដិវត្តន៍នេះមានការបង្ខំខ្លះអត់ខ្លះ ពីព្រោះអ្នកខ្លះមានបំណងចូលរួមកសាងជាតិ ហើយអ្នកខ្លះទៀតត្រូវបានគេបង្ខំឲ្យចូលរួមធ្វើបដិវត្តន៍ ដោយឲ្យពួកគេយកទ្រព្យធន់ខ្លះដើម្បីផ្គត់ផ្គង់បដិវត្តន៍ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបន្ថែមថា នៅមុនឆ្នាំ១៩៧៥ ខ្លួនគឺជាអ្នករត់សំបុត្រឲ្យកម្មាភិបាលតូចធំ ជាពិសេសរត់សំបុត្រឲ្យឈ្មោះ វ៉ាន់ ដែលជាគណៈភូមិភាគឦសាន្ត ។

ក្រោយពីសហព្រះរាជអាជ្ញា សួរលោក រម៉ាម យុន ប្រធានអង្គជំនុំជម្រះសម្រេចផ្អាក នីតិវិធីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយចាប់ផ្តើមសួរទៅលើសាក្សី ឡុង នរិន្ទ ។

នៅក្នុងសវនាការនោះ សហមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុមមិនទាន់មានឱកាសក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះឡើយ ដោយសារតែការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះត្រូវបានផ្អាកនៅត្រឹមពាក់កណ្តាលទី ។ អង្គជំនុំជម្រះបានប្រកាសថា នីតិវិធីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបនេះនឹងត្រូវធ្វើបន្តនៅខែមករា ឆ្នាំ២០១២ ។ មូលហេតុដែលនាំឲ្យមានការប្រកាសផ្អាក់នីតិវិធីសួរដេញដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនេះ ដោយសារតែបញ្ហាសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបមានការចុះខ្សោយ ។ ជាពិសេសជាងនេះទៅទៀត អង្គជំនុំជម្រះទុកពេលវេលានេះដើម្បីសួរយកចម្លើយរបស់សាក្សី គឺលោក ឡុង នរិន្ទ ដែលអង្គជំនុំជម្រះគត់សម្គាល់ថាជាការចាំបាច់ដែលត្រូវស្តាប់សក្ខីកម្មរបស់លោក ឡុង នរិន្ទ មុន ដោយសារសាក្សីរូបនេះមានវ័យចាស់ជរាហើយថែមទាំងមានជម្ងឺថែមទៀត ។

## គ) ការសួរដេញដោលសាក្សី

នៅក្នុងនីតិវិធីនៃសវនាការលើកស្តុតាងក្នុងដំណាក់កាលទីមួយ អង្គជំនុំជម្រះសាលាដំបូងបានបើកការសាកសួរសាក្សីទីមួយ គឺលោក ឡុង នរិន្ទ ដែលជាអតីតបុគ្គលិកនៅក្រសួងការបរទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាសាក្សីដាក់បន្ទុករបស់សហព្រះរាជអាជ្ញា ។ ការសួរដេញដោលសាក្សី ឡុង នរិន្ទ ធ្វើឡើងនៅក្រោយការផ្អាកការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបខាងលើដោយសារតែបញ្ហាសុខភាព ។ ការបើកសវនាការសួរដេញដោលសាក្សី ឡុង នរិន្ទ មុនគេត្រូវបានអង្គជំនុំជម្រះផ្តល់ហេតុផលថាដោយសារសាក្សីរូបនេះមានវ័យជរា និងមានបញ្ហាសុខភាព ។ ម៉្យាងវិញទៀត ដោយសារបញ្ហាសុខភាព វ័យចាស់ជរា និងមានជំងឺប្រចាំកាយ អង្គជំនុំជម្រះ

បានសម្រេចអនុញ្ញាតឲ្យសាក្សីរូបនេះអាចធ្វើសក្ខីកម្មពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ ពីលំនៅដ្ឋានរបស់លោកនៅខេត្តបន្ទាយមានជ័យ ដោយមានការសម្របសម្រួលពីសំណាក់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ។ នៅអំឡុងពេលធ្វើសក្ខីកម្ម បុគ្គលិករបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញម្នាក់ ត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះឲ្យអង្គុយនៅជិតសាក្សី ឡុង នរិន្ទ ដើម្បីជួយសម្រួល និងបញ្ជាក់សំណួរទាំងឡាយដែលសាក្សីរូបនេះមិនអាចស្តាប់ឮ ឬលំបាកយល់អំពីសំណួរទាំងឡាយដែលចៅក្រម និងភាគីនៃសវនាការចោទសួរ ។ លោក ឡុង នរិន្ទ ត្រូវបានអង្គជំនុំជម្រះសាកសួរដេញដោលអំពីប្រវត្តិសាវតាររបស់លោកតាំងពីពេលមុននៃរបបកម្ពុជាប្រជាធិបតេយ្យ រហូតដល់ការដួលរលំនៃរបបខ្មែរក្រហម ។ ប៉ុន្តែដោយសារបញ្ហាបច្ចេកទេសនៃប្រព័ន្ធសោតទស្សន៍ និងបញ្ហាសុខភាព តម្រូវឲ្យសាក្សីរូបនេះស្នើសុំអង្គជំនុំជម្រះចូលបន្ទប់ទឹកជាញឹកញាប់ ដែលបណ្តាលឲ្យការផ្តល់សក្ខីកម្មពីចម្ងាយនេះមានសភាពរអាក់រអួល និងមានភាពយឺតយ៉ាវ ។

លោក ឡុង នរិន្ទ បានឆ្លើយតបជាច្រើនទៅសំណួររបស់អង្គជំនុំជម្រះ និងភាគីនៃសវនាការដែលចោទសួរមកលើខ្លួនទាក់ទងនឹងប្រវត្តិសិក្សា និងប្រវត្តិការងារដែលធ្លាប់បានធ្វើការជាមួយនឹងជនជាប់ចោទ អៀង សារី និងជនជាប់ចោទ អៀង ធីរិទ្ធនៅមុនពេល អំឡុងពេល និងក្រោយពេល នៃរបបកម្ពុជាប្រជាធិប




និស្សិតកំពុងមើលប្រវត្តិរូបមេដឹកនាំខ្មែរក្រហមទាំងបី

តេយ្យ ។

## ប្រវត្តិសាវតារ

នៅអំឡុងពេលនៃការសាកសួរដេញដោល លោក ឡុង នរិន្ទ បានលើកឡើងថា លោកកើតនៅក្នុងឆ្នាំ១៩៣៨ បច្ចុប្បន្នរស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ លោក ឡុង នរិន្ទ ហៅ រិទ្ធ ជាអតីតនិស្សិតធ្លាប់បានទៅសិក្សានៅប្រទេសឆេកូស្លូវ៉ាគី រយៈពេល១០ឆ្នាំ ក្នុងអំឡុងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧០ ឬ១៩៧១ ខាងផ្នែកកាយ អប់រំ កីឡា និងប្រាណ ។

បន្ទាប់ពីការអំពាវនាវរបស់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០ លោក នរិន្ទ បាន ត្រឡប់មកពីប្រទេសឆេកូស្លូវ៉ាគី



រួចធ្វើការនៅទីក្រុងប៉េកាំងមួយរយៈ ។ នៅទីក្រុងប៉េកាំង លោកបានចូលរួមក្នុងចលនាមួយដែលមានសម្តេចនរោត្តម សីហនុ ជាប្រធាន ។ នៅទីនោះលោកបានធ្វើការនៅក្នុងក្រសួងការបរទេសនៃរដ្ឋាភិបាលរួបរួមជាតិរបស់សម្តេចសីហនុ ដោយមានតួនាទីជាអ្នកវាយអត្ថបទ បកប្រែភាសា និង វាយសំបុត្រផ្សេងៗសម្រាប់ទាក់ទងពីប្រទេសមួយទៅប្រទេសមួយ និងពីចលនាមួយទៅចលនាមួយ ។ ក្រោយពីចាកចេញពីទីក្រុងប៉េកាំង លោក ឡុង នរិន្ទ បានមកបម្រើការងារនៅក្នុងស្ថានីយវិទ្យុរណៈសិរ្សរួបរួមជាតិប្រជាធិបតេយ្យ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដោយមាន អៀង ធីរិទ្ធ ជាអ្នកគ្រប់គ្រង ។ លោក នរិន្ទ បានអះអាងថា លោកបានចូលបម្រើការនៅទីនោះដោយស្ម័គ្រចិត្ត បន្ទាប់ពីឮជនជាប់ចោទ អៀង សារី និយាយថាវិទ្យុនេះក៏ជាការតស៊ូមួយដែរ "ធ្វើការនៅទីនោះហើយចាំត្រឡប់ទៅស្រុកវិញក៏បាន" ។ នៅអំឡុងពេលបម្រើការនៅស្ថានីយវិទ្យុនោះ លោក នរិន្ទ បានបញ្ជាក់ថា ខ្លួនមានមុខងារជាអ្នកបកប្រែសំបុត្រដែលមានលេខសម្ងាត់មកជាភាសាខ្មែរដើម្បីផ្សព្វផ្សាយទៅក្នុង និងក្រៅប្រទេស និងបានធ្វើជាអ្នកអប់រំសិស្សដែលមានឪពុកម្តាយធ្លាប់រស់នៅទីក្រុងហាណូយទៀតផង ។ ក្រោយពីចាកចេញពីទីក្រុងហាណូយ លោក នរិន្ទ បានត្រឡប់មកប្រទេសកម្ពុជាវិញ និងចូលបម្រើការងារនៅក្រសួងការបរទេសនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យដែលមាន អៀង សារី ជារដ្ឋមន្ត្រី។ សាក្សីរូបនេះបានបន្តថា នៅដំណាក់កាលនោះ ក្រសួងការបរទេសត្រូវបានគេហៅថាជាមន្ទីរប-១ នៅទីនោះខ្លួនមានមុខងារជាអ្នកវាយអត្ថបទ និងធ្វើការងារពាក់ព័ន្ធនឹងលិខិតឆ្លងដែនសម្រាប់អ្នកដែលចេញចូលប្រទេសកម្ពុជា ។ ជាងនេះទៅទៀត លោក នរិន្ទ ធ្លាប់បានទៅបម្រើការនៅមន្ទីរប-២០អស់រយៈពេលប្រហែល៦ខែនិងក្រោយមកនៅមន្ទីរ ប-១៥ ។ នៅអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យដដែលនេះ លោក ឡុង នរិន្ទ ក៏ធ្លាប់ត្រូវបានចែងតាំងឲ្យបម្រើការនៅក្នុងព្រះបរមរាជវាំង ដោយមានមុខងារជាអ្នកការពារសម្តេច នរោត្តម សីហនុ ខណៈដែលទ្រង់គង់នៅជាព្រះប្រធានរដ្ឋអស់រយៈពេលប្រហែល៦ខែ ។

### ទំនាក់ទំនងរវាងសាក្សី ឡុង នរិន្ទ ទាំងជនជាប់ចោទ អៀង សារី និងបុគ្គលផ្សេងទៀត

សាក្សី ឡុង នរិន្ទ បានបញ្ជាក់ថា នៅខណៈពេលដែលលោកធ្វើការនៅមន្ទីរប-១ លោកត្រូវបានអង្គការសង្ស័យថាជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ សេ.អ៊ី.អា ។ នៅពេលនោះ ជនជាប់ចោទ អៀង សារី បានបង្គាប់ឲ្យលោកសរសេរប្រវត្តិរូបផ្ទាល់ខ្លួនរួចផ្ញើជូនទៅជនជាប់ចោទ អៀង សារី តាមរយៈលោក សួង ស៊ីគឿន ដែលជាមេក្រុមរបស់ខ្លួន ។ សាក្សីរូបនេះបានបន្តថា ខ្លួនស្គាល់ជនជាប់ចោទ អៀង សារី ដំបូងតាមរយៈលោក ថាច់ ជា គឺជាមិត្តភក្តិរៀនជាមួយគ្នានៅពេលជនជាប់ចោទ អៀង សារី និងភរិយាគឺជនជាប់ចោទ អៀង ធីរិទ្ធ ធ្វើដំណើររួមគ្នាជាមួយគ្រួសារទៅក្រៅប្រទេស ។ កាលនោះលោកគ្រាន់តែស្គាល់ឈ្មោះ អៀង សារី ប៉ុណ្ណោះ មិនទាន់មានទំនាក់ទំនងជាមួយគ្នានៅឡើយទេ ។ បន្ទាប់មកលោកបានជួបនឹងជនជាប់ចោទ អៀង សារី នៅទីក្រុងហាណូយ នៅខណៈពេលដែលជនជាប់ចោទ អៀង សារី បានធ្វើខទ្ទេសនាមនៅក្នុងកិច្ចប្រជុំនៅទីនោះ ។ ជនជាប់ចោទ អៀង សារី ធ្លាប់បានប្រជុំប្រាប់បុគ្គលិកនៅក្នុងក្រសួងការបរទេសថា ខ្លួននឹងមិន អនុញ្ញាតឲ្យនរណា

ម្នាក់នាំយកបុគ្គលិកនៃក្រសួងនេះចេញទៅណាដាដាច់ខាត នៅពេល ដែលខ្លួនមិននៅ ។ លោក ឡុង នរិន្ទ បានរៀបរាប់ប្រាប់អង្គជំនុំជម្រះថា ខ្លួនមិនមានទំនាក់ទំនងជាមួយជនជាប់ចោទ អៀង សារី ទៀតទេបន្ទាប់ពីឆ្នាំ១៩៧៩ ហើយក៏មិនដឹងថា អៀង សារី រស់នៅទីណាដែរនៅពេលបច្ចុប្បន្ននេះ ។ ប៉ុន្តែនៅក្នុងការលើកឡើងរបស់សហព្រះរាជអាជ្ញាបានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៩៤ លោក នរិន្ទ ធ្លាប់មានតួនាទីជាអគ្គលេខាធិការនៃចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ដែលមានជនជាប់ចោទ អៀង សារី ជាប្រធាន ។ លោក នរិន្ទ បានឲ្យដឹងថា ចលនានេះនៅតែមានដល់សព្វថ្ងៃ ប៉ុន្តែ មិនមានសកម្មភាពអ្វីទេ ។

នៅពេលដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ខេល លីសាក់ សួរថាតើ ថាច់ ជា ជានរណា លោក នរិន្ទ បានឆ្លើយតបថាឈ្មោះ ថាច់ ជា ជាអ្នកដែលធ្លាប់រៀននៅសាលាជាមួយ គ្នា និងធ្លាប់លេងបាល់នៅក្នុងក្រុមជាមួយគ្នា ហើយក៏ជាបុគ្គលម្នាក់ដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល លន់ នល់ ។ ប៉ុន្តែលោក មិនបានបញ្ជាក់អំពីមុខងាររបស់បុគ្គលនេះទេ ។ លោក នរិន្ទ បានផ្តល់សក្ខីកម្មទៀតថា ដោយសារពេលវេលាកន្លងមកយូរណាស់ទៅហើយ ដូចនេះលោកមិនច្បាស់ទេថា តើបុគ្គលនេះត្រូវបានកូនសិស្សចាប់ផ្តើមចំណាប់ខ្មាំងនៅឆ្នាំ១៩៧៤ និងក្រោយមកត្រូវបានបាញ់សម្លាប់ជាមួយរដ្ឋ មន្ត្រីក្រសួងអប់រំនោះ ឬយ៉ាងណា ។ សាក្សីរូបនេះបានបញ្ជាក់អំពីមូលហេតុដែលខ្លួនបានហៅឈ្មោះ ថាច់ ជា ថា “អា ថាច់ ជា” នៅក្នុងប្រវត្តិរូបរបស់ខ្លួនជូនទៅអង្គជំនុំជម្រះក៏ដូចជាសហព្រះរាជអាជ្ញាដែលកំពុងសួរអំពីបញ្ហានេះ ថា ខ្លួនហៅបែបនេះ គឺដោយសារតែមានមិត្តភាពជិតស្និតជាមួយគ្នា ។ លោក នរិន្ទ បានបញ្ជាក់បន្តថា លោកបានដឹងរឿងរបស់ឈ្មោះ ថាច់ ជា ជាភ្នាក់ងារស៊ើបការណ៍ សេ.អ៊ី.អា ដោយសារឈ្មោះនេះតែងតែទៅស្ថានទូតអាមេរិកដែលជាប្រទេសសេរី ខុសស្រឡះពីខ្លួនដែលតែងតែទាក់ទងជាមួយប្រទេសអព្យាក្រឹត្យ និងប្រទេសសង្គមនិយម ។

នៅពេលដែលធ្វើការសាកសួរអំពីទំនាក់ទំនងជាមួយនិងកម្មាភិបាលខ្មែរក្រហមដទៃទៀត ដែលមានឈ្មោះនៅក្នុងប្រវត្តិរូបរបស់ខ្លួន លោក ឡុង នរិន្ទ ដែលជាសាក្សីខាងព្រះរាជអាជ្ញាត្រូវបានសហព្រះរាជអាជ្ញារងអន្តរជាតិសួរម្តងហើយម្តងទៀតអំពីភាពស្មុគស្មាញក្នុងការឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលចោទសួរមកលើខ្លួន ។ សហព្រះរាជអាជ្ញារង លោក ខេល លីសាក់ បានបង្ហាញពីភាពមន្ទិលទៅនឹងចម្លើយរបស់សាក្សី មានពេលខ្លះសហព្រះរាជអាជ្ញាយល់ថាសាក្សីព្យាយាមមិនបញ្ចេញឈ្មោះអតីតប្រធានរបស់ខ្លួនគឺជនជាប់ចោទ អៀង សារី នោះទេ ។ លោក ឡុង នរិន្ទក៏ត្រូវបានសហព្រះរាជអាជ្ញាសួរដេញដោលពីទំនាក់ទំនងរបស់ខ្លួនជាមួយបុគ្គលមួយចំនួនទៀត ដែលបុគ្គលទាំងនោះរួមមាន៖

១) តូច ខាំឿន និង ហាក់សៀង ឡាយនី អតីតបុគ្គលិកនៅក្រសួងការបរទេសជាមួយគ្នា ក្រោយមកត្រូវបានចាប់ខ្លួន ។

២) ទេព សំអាត អតីតអគ្គរដ្ឋទូត ធ្លាប់ធ្វើការនៅប៉េកាំងជាមួយគ្នា ក្រោយមកត្រូវគេបញ្ជូនទៅមន្ទីរស-២១ ។

៣) វ៉ាន់ ពិនី ជាអតីតលេខាទី២ នៅទូតអេហ្ស៊ីប ធ្លាប់ធ្វើការជាមួយគ្នានៅប៉េកាំង ។

៤) គាត ឈន់ អតីតបុគ្គលិកនៅក្រសួងការបរទេសជាមួយគ្នា ប៉ុន្តែនៅផ្នែកនិពន្ធ ។

៥) ជួន ប្រសិទ្ធ ធ្លាប់ធ្វើការជាមួយគ្នា ។

៦) ឈន ហៃ អតីតធ្វើជាកងការពារសម្តេច នរោត្តម សីហនុ នៅក្នុងវាំង ។

៧) លោក ហាក់ សៀងឡាយនី ត្រូវបានអង្គការចាប់ទាំងប្តីប្រពន្ធ

៨) សារិន ឆាក ធ្លាប់ធ្វើការជាមួយនៅទីក្រុង ប៉េកាំង ។

៩) សូ ហុង ជាក្មួយរបស់ ប៉ុល ពត ដែលមានតែឈ្មោះនៅក្រសួងការបរទេស ។

លោក ឡុង នរិន្ទ បានបញ្ជាក់ថា នៅខណៈពេលដែលខ្លួនធ្វើការនៅក្នុងមន្ទីរប-១ លោកតែងតែមានការភ័យខ្លាចចំពោះពាក្យថា “ទៅរៀនសូត្រ” ដោយសារនៅពេលនោះ ការបញ្ជូនទៅរៀនសូត្រ គឺគេបញ្ជូនទៅមន្ទីរសន្តិសុខស-២១ និងសាខារបស់មន្ទីស-២១ ដូចជាមន្ទីរបឹងត្របែក និងមន្ទីរប្រាំងចំរេះ ។

សហព្រះរាជអាជ្ញា លោក ខេល លីសាក់ បានស្នើសុំឲ្យសាក្សី ឡុង នរិន្ទ ពន្យល់អំពីឃ្លាមួយ ដែលបានសរសេរនៅក្នុងប្រវត្តិរូបសង្ខេបរបស់ខ្លួនថា៖

“ក្នុងរយៈកាលសិក្សាជីវិតរបស់ខ្ញុំគឺខ្មៅងងឹតស្ងួនស្ងុប ទាក់ទងនឹងពួកដែលក្រោយមកក្បត់ប្រទេសជាតិ និងចូលដៃនឹងពួកអាក្បត់ ។ ម្យ៉ាងទៀតការរស់នៅក៏មិនស្អាតស្អំ គឺដូរលុយកាក់រកស៊ីចងការមានបាន ។ សីលធម៌នារីបុរសក៏មិនស្អាតស្អំ ។ ដោយសារគុណអង្គការ យើងខ្ញុំបានវិលមករកផ្លូវត្រូវផ្លូវបដិវត្តន៍កម្ពុជា ។ ខ្ញុំបានខិតខំកសាងខ្លួនតាមការណែនាំរបស់អង្គការ” ។

នៅត្រង់ចំណុចនេះសាក្សី ឡុង នរិន្ទ បានពន្យល់ថាការសរសេរនោះគឺគ្រាន់តែចង់បញ្ជាក់ថាខ្លួនស្មោះត្រង់នឹងអង្គការប៉ុណ្ណោះ មិនមានលាក់លៀមអីទេ ហើយកាលនៅរៀនវាមានរឿងបែបហ្នឹងនាំឲ្យពេលបដិវត្តន៍គឺត្រូវខំប្រឹងកែខ្លួន ។ ឆ្លើយតបទៅនឹងសំណួរដែលលោកសហព្រះរាជអាជ្ញាសួរថាតើលោកមានដឹងទេថាឈ្មោះដែលបានលើកឡើងនៅក្នុងប្រវត្តិរូបរបស់លោកនោះចុងក្រោយគឺត្រូវបានគេនាំយកទៅកាន់មន្ទីរស-២១ ។ លោក ឡុង នរិន្ទ បានឆ្លើយថាខ្លួនមិនដឹងពីមូលហេតុដែលគេឲ្យសរសេរប្រវត្តិរូបនេះទេ ហើយក៏មិនដឹងថាមានរឿងអ្វីបន្ទាប់ពីការសរសេរនេះដែរ ប៉ុន្តែលោកមានជំនឿថា ប្រហែលជាអង្គការចង់ដឹងពីទំនាក់ទំនងរបស់ខ្លួនជាមួយនរណាខ្លះ ។

នៅក្នុងសវនាការនៃការផ្តល់សក្ខីកម្មដោយសាក្សី ឡុង នរិន្ទ ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន មិនមានសំណួរសាកសួរទៅសាក្សីរូបនេះឡើយ ។ មានតែក្រុមមេធាវីការពារក្តីជនជាប់ ចោទ នួន ជា និងក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ប៉ុណ្ណោះ ដែលបានសួរដេញដោល ។

នៅមុនពេលបញ្ចប់ការសួរដេញដោលសាក្សី លោក ឡុង នរិន្ទ មានចំណុចដែលគួរកត់សម្គាល់មួយគឺថា ជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះដើម្បីសួរសាក្សី ឡុង នរិន្ទ ។ ជនជាប់ចោទ នួន ជា បានសួរសំណួរទៅសាក្សី ឡុង នរិន្ទ ដោយសំដីមាំៗអំពីការទទួលឥទ្ធិពលពី ស៊ឺង ង៉ុកថាញ់ ដែលជាអ្នកប្រឆាំងនឹងព្រះមហាក្សត្រ ។ លោក នរិន្ទ ឆ្លើយតបបដិសេធដោយសំដីមួយៗថាខ្លួនមិនបានទទួលឥទ្ធិពលពី ស៊ឺង ង៉ុកថាញ់ ទេ ។ ខ្លួនពេញចិត្តនឹងការតស៊ូរបស់លោក ស៊ឺង ង៉ុកថាញ់ ចំពោះការតស៊ូប្រឆាំងនឹងបារាំងឯសកម្មភាពផ្សេងទៀត គឺអត់ទេ ។ ជនជាប់ចោទ នួន ជា ចោទសួរបន្តទៀតថា តើលោកធ្លាប់មាននិយាយថាមានសមានចិត្តចំពោះ ស៊ឺង ង៉ុកថាញ់ ដោយសារបុគ្គល នេះប្រឆាំងនឹងស្តេច និងអាណានិគមបារាំងដែរឬទេ? លោក ឡុង នរិន្ទ បានឆ្លើយតបថាកាលនោះយុវជនខ្មែរគឺអឺចឹង ចេះតែជយោទៅ តែក្រោយមកបានទទួលការអប់រំទើបដឹងថាការធ្វើបែបនេះមិនល្អ ។ ជនជាប់ចោទ នួន ជា បានបន្តសំណួររបស់ខ្លួនទៀតថាតើលោកមានជាប់និន្នាការនយោបាយជាមួយ ហង់ ធុនហាក់ ដែលជាដៃស្តាំរបស់ ស៊ឺង ង៉ុកមិញ និងក្រោយមកនៅឆ្នាំ១៩៧២ ឡើងជានាយករដ្ឋមន្ត្រីនោះដែរទេ? តើលោកស្គាល់ អៀ ស៊ីចូវ ដែលជាដៃស្តាំរបស់ ស៊ឺង ង៉ុកថាញ់ ទេ? និងសំណួរចុងក្រោយថាតើឈ្មោះទាំងអស់ដែលលោកបានលើកនៅក្នុងប្រវត្តិរូបរបស់លោកនោះ តើពួកនេះមានធ្វើសកម្មភាពជាមួយ ស៊ឺង ង៉ុកថាញ់ ទេ? តើសកម្មភាពអ្វីខ្លះ? លោក ឡុង នរិន្ទ បានបដិសេធទៅនឹងសំណួរទាំងអស់ខាងលើរបស់ នួន ជា ជាមួយនឹងពាក្យថា មិនដឹង និងមិនស្គាល់ ។

## សេចក្តីសន្និដ្ឋាន

សវនាការស្តីពីការសួរដេញដោល និងពិនិត្យភស្តុតាងដែលរៀបចំឡើងដោយអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ គឺគ្រាន់តែជាសវនាការដំណាក់កាលដំបូងដែលផ្តោតលើប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា និងសាវតាររបស់ជនជាប់ចោទម្នាក់ៗដែលយកចេញពីផ្នែកមួយនៃដីកាដំណោះស្រាយ ដើម្បីចោទសួរជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញតែប៉ុណ្ណោះ ។ បន្ទាប់ពីបញ្ចប់ការសួរដេញដោលទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និងសាវតាររបស់ជនជាប់ចោទ អង្គជំនុំជម្រះនឹងបន្តយកអង្គហេតុផ្សេងទៀតនៃដីកាដំណោះស្រាយមកពិភាក្សាសួរដេញដោល និងពិនិត្យភស្តុតាងដែលទាក់ទងនឹងអង្គហេតុទាំងនោះ ។

ការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងនៅអំឡុងពេលសវនាការបានជួបប្រទះនូវបញ្ហាមួយចំនួន ដោយសារតែអង្គជំនុំជម្រះមានភាពលំបាកក្នុងការកំណត់បែងចែកពេលវេលាសម្រាប់ភាគីនានាក្នុងការសួរដេញដោលនៅក្នុងសវនាការ ដែលជាហេតុធ្វើឲ្យមានការពន្យារពេលការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងជនជាប់ចោទនៅអំឡុងពេលសវនាការ ។ ម្យ៉ាងវិញទៀត បញ្ហាសុខភាព វ័យចាស់ជរារបស់ជនជាប់ចោទ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី បញ្ហា

បច្ចេកទេសក្នុងការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍ដើម្បីសាកសួរសាក្សី និងការជំទាស់របស់ភាគីនៅក្នុងអំឡុងពេលសវនាការក៏បានបង្កភាពលំបាកទៅដល់អង្គជំនុំជម្រះ និងបានទាញដំណើរការនីតិវិធីមិនឲ្យទៅមុខលឿនដូចដែលអង្គជំនុំជម្រះចង់បានឡើយ ។

ទោះជាយ៉ាងណា សវនាការស្តីពីការសួរដេញដោល និងពិនិត្យលើភស្តុតាងដែលប្រព្រឹត្តធ្វើឡើងនាពេលនេះ គឺជាដំណើរវិវឌ្ឍន៍ថ្មីមួយទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ និងការពិត ដែលប្រជាជនកម្ពុជាទូទាំងប្រទេសបានទន្ទឹងរង់ចាំអស់រយៈពេលជិត៣២ឆ្នាំ ។

## បញ្ហាផ្សេងៗ

នៅអំឡុងពេលនៃការអានអង្គហេតុដែលមាននៅក្នុងដីកាដំណោះពីសំណាក់ក្រឡាបញ្ជីនៃអង្គជំនុំ ជម្រះ ជនជាប់ចោទ ខៀវ សំផន បានស្តាប់ការអានអង្គហេតុចោទប្រកាន់ប្រឆាំងនឹងខ្លួនដោយយកចិត្តទុកដាក់ ហើយនៅរៀងរាល់ពេល ជនជាប់ចោទរូបនេះបានឱនមុខសរសេរនៅលើក្រដាស ដែលដាក់នៅលើតុរបស់ខ្លួនដើម្បីត្រៀមធ្វើការឆ្លើយតបទៅនឹងការចោទប្រកាន់ទាំងនោះ ។ មានពេលខ្លះ ជនជាប់ចោទរូបនេះបានងាកទៅពិភាក្សាជាមួយមន្ត្រីសំណុំរឿងដែលអង្គុយនៅជិតខ្លួនជាញឹកញាប់ ។

ក្នុងសវនាការលើភស្តុតាងកាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ ដែលធ្វើការពិភាក្សាដេញដោលអំពីប្រវត្តិរបស់បក្សកុម្មុនីស្តកម្ពុជា និងប្រវត្តិសាវតាររបស់ជនជាប់ចោទ អង្គជំនុំជម្រះបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូបដើម្បីធ្វើការសាកសួរ ។ នៅក្នុងកិច្ចដំណើរការនីតិវិធី សហមេធាវី អន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក ម៉ៃឃើល ដេស្តមែន បានស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើសម្បថមុនពេលផ្តល់សក្ខីកម្មនេះ ។ ឆ្លើយតបទៅនឹងការលើកឡើងខាងលើ លោកចៅ ក្រម និល ណុន បានបញ្ជាក់ដោយសំដីច្បាស់ៗថា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរឆ្នាំ២០០៧ និងវិធានផ្ទៃក្នុងរបស់អង្គជំនុះជម្រះក្នុងតុលាការកម្ពុជា មិនតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការស្បថឡើយ ។ លោក ពេជ អង្គ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបដិសេធចំពោះការលើកឡើងរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា ថាដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីនៅក្នុងសំណុំរឿង ដូច្នេះគាត់មានសិទ្ធិនិយាយទាំងអង្គហេតុ និងអង្គច្បាប់ នៅក្នុងពេលធ្វើសក្ខីកម្ម ។ លោកមេធាវី ពេជ អង្គ បានបន្តទៀតថា នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មអំពីអង្គហេតុ គឺមិនវិធានណាមួយអាចកែប្រែឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យទៅជាសាក្សីបានឡើយ ។ ឆ្លើយតបទៅនឹងបញ្ហានេះ លោកចៅក្រម ហ្សង់ម៉ាក ឡាវែង ក៏បានលើកឡើងអំពីច្បាប់កម្ពុជាដែលចម្លងចេញពីច្បាប់បារាំង គឺចាត់ទុកដើមបណ្តឹងរដ្ឋប្បវេណីជាភាគីមួយនៅក្នុរឿងក្តី ។ លោកចៅក្រមរូបនេះបានបន្តទៀតថា ដោយសារឋានៈនេះដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់ស្បថនោះទេ ហើយអាចផ្តល់សក្ខីកម្មអំពីព្យសនកម្មដែលខ្លួនទទួលរង ឬអង្គហេតុដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទបាន ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១ នៅពេលអង្គជំនុំជម្រះធ្វើការសាកសួរទៅលើដើមបណ្តឹងរដ្ឋប្បវេណី មេធាវីអន្តរជាតិរបស់ជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ខាណាវ៉ាស បានធ្វើការកត់សម្គាល់និងស្នើសុំទៅអង្គជំនុំជម្រះម្តងហើយម្តងទៀតអំពីការសុំឲ្យមានការហាមឃាត់ចំពោះការប្រាស្រ័យទាក់ទងគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងមេធាវីខ្លួននិងអ្នកផ្សេងទៀត ។ លោកមេធាវី ខាណាវ៉ាស បានបន្តថា ការប្រាស្រ័យទាក់ទងនោះអាចនឹងនាំឲ្យមានការប៉ះពាល់ដល់ការធ្វើសក្ខីកម្ម ដោយសារតែការផ្តល់សក្ខីកម្មរបស់បុគ្គលនោះមិនទាន់បានបញ្ចប់នៅឡើយ ។ លោក កាណាវ៉ាស បានផ្តល់ហេតុផលថា នៅក្នុងច្បាប់បារាំង ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើការទាក់ទងជាមួយមេធាវីបានទេក្នុងពេលសវនាការដែលការណ៍នេះវាមានលក្ខណៈផ្ទុយពីជនជាប់ចោទ ។ ឆ្លើយតបទៅនឹងចំណុចទាំងនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកពេជ អង្គ បានឆ្លើយតបថា នៅក្នុងករណីនេះមិនគួរមានការបែងចែកសិទ្ធិឲ្យមានលក្ខណៈខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់ខ្លួនឡើយ ។ លោកពេជ អង្គ បានអះអាងថា វានាំឲ្យមានភាពមិនស្មើគ្នា ដោយសារជនជាប់ចោទមានសិទ្ធិប្រឹក្សាយោបល់ជាមួយមេធាវីនៅគ្រប់ដំណាក់កាល ចំណែកដើមបណ្តឹងរដ្ឋប្បវេណីបែរជាមិនមាននោះ ។ លោកមេធាវីបន្តទៀតថាគ្មានវិធានណាមួយដែលហាមឃាត់មិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីជួប

ជាមួយមេធាវីរបស់ខ្លួននៅក្នុងករណីនេះទេ ។ បន្ថែមទៅលើការលើកឡើងរបស់លោក ពេជ អង្គ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក មេងឃី បានធ្វើការជំទាស់ទាំងស្រុងទៅលើការលើកឡើងរបស់មេធាវីការពារក្តី លោក ខាណាវ៉ាស ថា ការធ្វើបែបនេះវានាំឲ្យខុសទៅនឹងទំនៀមទម្លាប់ក្នុងការអនុវត្តច្បាប់នៅកម្ពុជា និងវិធានផ្ទៃក្នុងដែលអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលការការពារផលប្រយោជន៍របស់ខ្លួននៅគ្រប់ដំណាក់កាល ។ ដូច្នេះការប្រាស្រ័យទាក់ទងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយមេធាវីរបស់ខ្លួន គឺជាសិទ្ធិមួយដែលគ្មាននរណាម្នាក់អាចជ្រៀតជ្រែកបានឡើយ ហើយសិទ្ធិនេះក៏ដូចជាសិទ្ធិប្រាស្រ័យទាក់ទងរបស់មេធាវីការពារជនជាប់ចោទជាមួយកូនក្តីរបស់ខ្លួនដែរ ។ ភ្លាមនោះ ដោយសារបញ្ហាដែលភាគីលើកឡើងមានលក្ខណៈដដែលៗលោកប្រធានចៅក្រម និល ណុន បានធ្វើការបញ្ជាក់អំពីវិធាន៨៨(២) ។ វិធាននេះកំណត់សម្រាប់តែជនជាប់ចោទ សាក្សី និងអ្នកជំនាញប៉ុណ្ណោះ ដែលមិនតម្រូវឲ្យមានការប្រាស្រ័យទាក់ទងគ្នា ហើយនេះគឺជាការបញ្ជាក់ឲ្យឃើញពីឋានៈខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ។ ដោយយោងទៅលើវិធាននេះដដែលដើមបណ្តឹងរដ្ឋប្បវេណីមិនតំរូវឲ្យស្បថនៅពេលធ្វើសក្ខីកម្ម ហើយគាត់មានសិទ្ធិទាមទារសំណងដែលសាក្សីពុំមានសិទ្ធិនេះឡើយ ។ លោកប្រធានអង្គជំនុំជម្រះ គ្រាន់តែបញ្ជាក់យ៉ាងខ្លីថាដើមបណ្តឹងរដ្ឋប្បវេណីអាចទាក់ទងជាមួយមេធាវីរបស់ខ្លួនដោយសេរី ។

នៅក្នុងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ខណៈពេលដែលសហព្រះរាជអាជ្ញាកំពុងតាំងសំណួរលើជនជាប់ចោទ នួន ជា អំពីសៀវភៅមួយក្បាលដែលមានបទសម្ភាសន៍ដែលជនជាប់ចោទរូបនេះបានធ្វើជាមួយនឹងលោក ថេត សម្បត្តិ មកធ្វើការសាកសួរដេញដោលលោកមេធាវី សុន អរុណ ដែលជាមេធាវីការពារឲ្យជនជាប់ចោទ នួន ជា បានធ្វើការបដិសេធទៅនឹងការលើកឡើងនោះ ។ លោកមេធាវី អរុណ បានអះអាងថា សៀវភៅនោះគឺមិនអាចយកជាការបានទេ ព្រោះមានភាសាតែមួយ គឺអង់គ្លេស ដោយមិនមានជាភាសាខ្មែរ និងបារាំង ។ លោកបន្តទៀតថា សៀវភៅនេះឃើញមានលក់នៅឯផ្សារ ហើយសៀវភៅនេះមិនដឹងថាសហព្រះរាជអាជ្ញាបានពីណាដើម្បីមកប្រើប្រាស់ជាផ្លូវការនោះទេ គឺខ្លួនមិនទទួលស្គាល់ជាផ្លូវការទេ ។ ពេលនោះលោកប្រធានអង្គជំនុំជម្រះយល់ថា ការជំទាស់របស់លោកមេធាវី សុន អរុណ សមស្រប ហើយបង្គាប់ឲ្យសហព្រះរាជអាជ្ញាមិនត្រូវសួរដេញដោលពីសៀវភៅដែលលើកឡើងនោះឡើយ ព្រោះសៀវភៅនេះមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ។ ការសួរទាក់ទងនឹងខ្លឹមសារនៅក្នុងសៀវភៅនេះអង្គជំនុំជម្រះមិនទាន់បានសម្រេចនៅឡើយ ។ ទាក់ទងនឹងបញ្ហានេះ លោកមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន បានស្នើទៅអង្គជំនុំជម្រះឲ្យកំណត់អំពីពេលវេលាសមស្របដែលអាចលើកយកបញ្ហានៃការដាក់ភស្តុតាងនេះមកសម្រេច ។ បន្ទាប់ពីការពិភាក្សារវាងចៅក្រមនៅក្នុងសវនាការរួចមក ប្រធាន អង្គជំនុំជម្រះលោកចៅក្រម និល ណុន ប្រគល់ភារកិច្ចទៅឲ្យលោកចៅក្រម ហ្សង់ម៉ាក ឡឺវែង ក្នុងការឆ្លើយតបទៅនឹងសំណើនេះ ។ លោកចៅក្រម ឡឺវែង បានឆ្លើយតបថា អង្គជំនុំជម្រះបានទទួលនូវការដាក់ឯកសារពីភាគីនោះ ហើយវាត្រូវការពេលវេលាជាច្រើនក្នុងការសម្រេច ។ ដូចនេះអង្គជំនុំជម្រះនឹងធ្វើការសម្រេចនៅដើមឆ្នាំក្រោយនេះ ដោយមានសវនាការពិសេសមួយសម្រាប់វិភាគទៅលើការបង្ហាញភស្តុតាង ធាតុផ្សំនៃភស្តុតាងដែលមានការពាក់ព័ន្ធមួយចំនួនទៅនឹងដីកាដំណោះស្រាយដើម្បីសម្រេចពីភាពទទួលយកបាននៃភស្តុតាងនិងការវាយតម្លៃនៃភស្តុតាងនីមួយៗ ។

នៅក្នុងអំឡុងពេលសវនាការស្តីពីការសួរដេញដោល និងពិនិត្យភស្តុតាង ឃើញថាមានការរអាក់រអួលផ្នែកបច្ចេកទេសមួយចំនួន ដោយពេលខ្លះអ្នកតាមដានដំណើរការនីតិវិធីពីសាលសវនាការសាធារណៈមិនបានទទួលសំឡេង ពេលខ្លះមានសំឡេងចេញពីបន្ទប់របស់អ្នកបកប្រែភាសា ដែលលើកឡើងថា ខ្លួនមិនបានទទួលសំឡេងពីក្នុងបន្ទប់សវនាការ ដែលត្រូវស្នើសុំទៅចៅក្រមឬភាគីឲ្យនិយាយសាជាថ្មីម្តងទៀត ។

## ប្រតិកម្មជុំវិញសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ

***ឈូក កែប អាយុ៥២ឆ្នាំ មកពីខេត្តពោធិ៍សាត់ នៅភូមិបឹងចក ឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។***

ខ្ញុំបានស្តាប់លោក នួន ជា ខ្ញុំគិតថាអ្វីដែលគាត់និយាយគឺ

បាត់ការពិតច្រើន ដូចដែលគាត់និយាយថា ក្នុងសម័យហ្នឹងឲ្យហូបមួយថ្ងៃបីពេល តែបើកាលនោះខ្ញុំនៅក្នុងរបបហ្នឹងដែរ គឺមិនដូចពាក្យគាត់ថាទេ ទោះបីនៅខេត្តពោធិ៍សាត់ធ្វើស្រូវបានច្រើន តែអត់ឲ្យប្រជាជនហូបគ្រប់គ្រាន់ទេ គឺឲ្យហូបបបរពីរពេលវ៉ាល់វែកចែកគ្នាមួយកំប៉ុង៤០នាក់ ។ នៅពេលគាត់និយាយថាដូចនេះ គឺខ្ញុំមានអារម្មណ៍ខឹង តែនឹកឃើញថាទប់ចិត្ត ហើយអ្វីដែលខ្ញុំចង់បានគឺឲ្យគាត់និយាយការពិត នៅពេលដែលគាត់និយាយថាអត់ដឹង ខ្ញុំដូចជាអន់ចិត្តព្រោះគ្រួសាររបស់ខ្ញុំត្រូវបានគេយកទៅសម្លាប់ចោល ហើយគ្រួសារបងស្រីរបស់ខ្ញុំត្រូវបានគេយកទៅសម្លាប់ទាំងអស់ដោយសារប្ដីរបស់គាត់ធ្លាប់ធ្វើទាហ៊ានលន់នល់ ។

***លោក សាន់ រុន មកពីឃុំឫស្សីក្រោស ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។***

លោក រុន បានមានប្រសាសន៍ថា ការណ៍ដែលលោក នួន ជា និយាយថាគាត់មិនដឹងពីការសម្លាប់នៅរបបកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំមិនជឿ ព្រោះគាត់ជាអ្នកកាន់ចង្កូត ដូចនេះបើគាត់មិនបញ្ជា នោះគ្មាននរណាហ៊ាន ។ ចំណែកការដែលគាត់និយាយថាមានការហូបគ្រប់គ្រាន់នោះ ខ្ញុំរឹតតែមិនជឿមួយរយភាគរយ ព្រោះនៅក្នុងការដ្ឋាននីមួយៗ អង្ករមួយកំប៉ុងត្រូវហូបពី៣០ទៅ៤០នាក់ក៏មាន គេឲ្យហូបបបរសុទ្ធតែទឹក គឺស្លាប់នឹងអត់បាយច្រើនណាស់ ។ មួយថ្ងៃគេឲ្យហូបតែពីរពេល គាត់និយាយភាគច្រើនជាពាក្យភូតភរ ការណ៍ដែលគាត់និយាយថារបបកម្ពុជាប្រជាធិបតេយ្យហូប១ថ្ងៃបីពេល ព្រឹក ថ្ងៃ ល្ងាច និងមានបង្អែម គឺនិយាយកុហក ព្រោះមិនដែលបានបង្អែមហូបទេ ។

***ម៉ាន សូត្រ អាយុ៧៨ឆ្នាំ មកពីស្រុកបារាយ ខេត្តកំពង់ធំ ។***

លោក សូត្រ បានចូលរួមស្ដាប់សវនាការ ហើយនៅពេលដែលគាត់បានលឺជនជាប់ចោទ នួន ជា និយាយពីការបរិភោគអាហារមួយថ្ងៃបីដង លោកមានប្រតិកម្មថា "ការណ៍ដែលគាត់និយាយថា របបអាហារ៣ពេលនោះ គឺវាអត់ត្រូវ ព្រោះជំនាន់នោះបានតែពីរពេលនោះពិបាកផង បបរទាំងព្រឹក ទាំងល្ងាច តែជួនកាលមានបាយខ្លះ ចំណែកបង្អែមមិនដែលមាន ។ ខ្ញុំមានអារម្មណ៍ខឹងព្រោះគាត់និយាយមិនត្រូវ ហើយពេលព្រះរាជអាជ្ញាសួរ គាត់តែងតែនិយាយពង្វៀងមិនឆ្លើយ ដូចនេះអ្វីដែលខ្ញុំចង់បាន គឺសុំឲ្យនិយាយតែត្រូវមកថា បើពីរពេលថាពីរពេល បើបីពេលថាបីពេលនិយាយយកតែត្រូវ" ។

***លីស សំបូរ ភេទប្រុស អាយុ៥៥ឆ្នាំ រស់នៅឃុំដប់វ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។***

ពេលឮ នួន ជា និយាយថាមួយថ្ងៃឲ្យបាយប្រជាជនហូបបីពេលនោះ ខ្ញុំមានការខឹងខ្លាំងណាស់ ពីព្រោះកាលជំនាន់នោះគេឲ្យខ្ញុំហូបតែបបរពីរពេលប៉ុណ្ណោះ ហើយមិនដែលមានបង្អែមអីនោះទេ តែបើពេលចូលឆ្នាំបានម្ដង ។ គេឲ្យយើងធ្វើការច្រើន តែមិនដែលបានហូបទេ ហើយការនិយាយបែបនេះ គឺជាការបោកប្រាស់យើងទេ ។ កាលនោះធ្វើស្រែបានច្រើនដែរ ប៉ុន្តែមិនដឹងថាគេយកស្រូវទៅណា ។

***ម៉ក់ វណ្ណី ភេទប្រុស អាយុ៥១ឆ្នាំ មុខរបរជាកសិករ រស់នៅភូមិស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។***

កាលជំនាន់ខ្មែរក្រហមខ្ញុំធ្វើការនៅក្នុងកងចល័តលើកអាងត្រពាំងថ្ម ហើយការហូបចុកជួបការលំបាកច្រើនមានតែបាយមួយចាន អត់មានម្ហូបទេ ហូបជាមួយទឹកប្រហុកដល់ក្រោយមកអត់មានបាយទេមានតែបបរហើយធ្វើការទាំងយប់ទាំងថ្ងៃ ។ ក្នុងរយៈពេលដែលគាត់កាន់អំណាចបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនោះ ខ្ញុំមិនដែលបានហូបបង្អែមទេ ហើយដល់ពេលឮគាត់និយាយអីចឹងខ្ញុំអន់ចិត្តក្ដៅក្រហាយណាស់ ព្រោះថាគាត់ជាអ្នកដឹកនាំទាំងមូលគាត់ថាមិនដឹង ហើយការនិយាយដូច្នេះ គ្រាន់តែជាការនិយាយដោះសារយករួចខ្លួនប៉ុណ្ណោះ ។

***ផង់ ចរិយា ភេទស្រី អាយុ២១ឆ្នាំ ជានិស្សិតនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ផ្នែកនីតិសាស្ត្រ ។***

ខ្ញុំយល់ថាការលើកឡើងរបស់ នួន ជា និយាយថាគាត់ការពារជាតិ ប៉ុន្តែខ្ញុំគិតថាការដែលគាត់ធ្វើនោះគឺការបំផ្លាញជាតិទៅវិញទេ ពីព្រោះបើគាត់ការពារជាតិគាត់មិនបណ្ដោយឲ្យប្រជាជនខ្មែរ ធ្លាក់ចូលទៅក្នុងរបបខ្មែរក្រហម ដែលនាំឲ្យមានការខូចខាតច្រើនទាំងជីវិតមនុស្ស ការបែកបាក់គ្រួសារ សាលារៀន មន្ទីរពេទ្យជាដើម ។ បើតាមស្ដាប់ឪពុកម្ដាយ គាត់ធ្លាប់ប្រាប់ខ្ញុំថានៅសម័យខ្មែរក្រហម គេធ្វើបាបប្រជាជន បង្អត់បាយ និងឲ្យធ្វើការច្រើន ។

## ■ តុលាការកំពូលសម្រេចបដិសេធការបង្គាប់ឱ្យដោះលែង អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌរបស់អង្គជំនុំជម្រះសាលាដំបូង

*នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន ចេញសេចក្តីសម្រេចមួយដោយមានមតិភាគច្រើនលើសលប់ សម្រេចបដិសេធលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានបង្គាប់ឲ្យដោះលែង ជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតមានលក្ខខណ្ឌ តាមពាក្យបណ្តឹងទៅអង្គជំនុំជម្រះតុលាការកំពូលរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។ នៅក្នុងបណ្តឹងឧទ្ធរណ៍នោះ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយផ្អែកទៅលើអង្គហេតុ និងអង្គច្បាប់ដែលមានកំហុស និងបានអនុវត្តន៍នូវឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនសមស្រប ។ សហព្រះរាជអាជ្ញាបានស្នើសុំទៅអង្គជំនុំ ជម្រះតុលាការកំពូលឲ្យធ្វើមោឃភាពទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌ និងស្នើសុំឲ្យកែប្រែទៅលើសេចក្តីសម្រេចនោះ ដោយបន្តដាក់ជនជាប់ចោទឲ្យនៅស្ថិតនៅក្នុងមន្ទីរឃុំឃាំងដើម្បីទទួលការពិនិត្យរោគវិនិច្ឆ័យឬការព្យាបាលផ្សេងៗ និងធ្វើការពិនិត្យសាជាថ្មីនៅរៀងរាល់៦ខែម្តង ដូចជាការណែនាំរបស់អ្នកជំនាញដែល ធ្លាប់បានធ្វើឡើងនៅក្នុងសវនាការ ។*

*ពាក់ព័ន្ធនឹងការកំណត់ពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ អង្គជំនុំជម្រះនៃតុលាការកំពូលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានមិនបានប្រឹងប្រែងឲ្យអស់ពីលទ្ធភាពក្នុងការចាត់វិធានការព្យាបាល ដូចដែលអ្នកជំនាញបានផ្តល់អនុសាសន៍ដើម្បីឲ្យសុខភាពស្មារតីរបស់ជនជាប់ចោទមានភាពប្រសើរឡើង ។*[១] *អង្គជំនុំជម្រះតុលាការកំពូលបានបន្ថែមថា «ដោយពិចារណាលើការរកឃើញរបស់អ្នកជំនាញវេជ្ជសាស្ត្រ និងដោយកត់សម្គាល់លើការកំណត់ពីសម្បទាក្នុងការចូលរួមសវនាការដែលជាបញ្ហាគតិយុត្ត អង្គជំនុំជំរះតុលាការកំពូលយល់ឃើញថា រាល់វិធានការដែលអាចធ្វើបានក្នុងការធ្វើឲ្យសុខភាពស្មារតីរបស់ជនជាប់ចោទប្រសើរឡើងនោះ មិនត្រូវបានរិះរកនោះទេ» ។*[២] *អង្គជំនុំជម្រះសាលាកំពូលបានផ្តល់សំអាងហេតុថា «យោបល់របស់វេជ្ជបណ្ឌិត ចន ខាំប៊ែល ដែលណែនាំឲ្យសាកល្បងប្រើថ្នាំ* Donepezil *អាចមានប្រសិទ្ធិភាពចំនួន៣៣ភាគរយ គឺបង្ហាញអំពីភវនីយភាពដែលមិនគួរត្រូវបានបដិសេធតាមទស្សនៈនៃផលប្រយោជន៍សាធារណៈនៅក្នុងការកាត់សេចក្តី» ។*[៣] *ក្រៅពីអនុសាសន៍របស់វេជ្ជបណ្ឌិត ចន ខាំប៊ែល អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅលើរបាយការណ៍របស់អ្នកជំនាញផ្នែកវិកលវិទ្យាដែលបានផ្តល់អនុសាសន៍ថា «ការរក្សាចំនួនបុគ្គលិក និងបុគ្គលិកដដែល ការរក្សាឲ្យមានបរិស្ថានដដែល ការបត់បែនដើម្បីសម្របទៅនឹងលទ្ធភាពប្រែប្រួលរបស់គាត់ ការធ្វើលំហាត់ប្រាណដោយមានការវាយតម្លៃ និងដំបូន្មានពីអ្នកឯកទេសព្យាបាលផ្នែកសរីរៈ នៅពេលដែលត្រូវការ និងការគាំទ្រការចូលរួមក្នុងសកម្មភាពដែល គាត់ពេញចិត្ត ។ បន្ថែមលើនេះកម្មវិធីជំរុញសតិបញ្ញាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវអាចជួយបានដែរ ប៉ុន្តែកម្មវិធីបែបនេះត្រូវអនុវត្តចំពោះអ្នកដែលបានទទួលការហ្វឹកហាត់ និងស្ថិតនៅក្រោមការត្រួតពិនិត្យ ។ បន្ថែមលើនេះ ការព្យាបាលជង្គង់ និងការឈឺចាប់ខ្នងរបស់ អៀង ធីរិទ្ធ និងការពិនិត្យតាមដានជាប្រចាំទៅលើសុខភាពរាងកាយរបស់គាត់ គឺជាការសំខាន់ដែលត្រូវធ្វើ ។ ការបន្តព្យាបាលលើ*

---

*[១] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ឯកសារលេខ* E138/1/7 *កថាខណ្ឌទី៣៧ (សេចក្តីសម្រេចរបស់តុលាការកំពូល ឯកសារលេខ* E138/1/7*) ។*

*[២] សេចក្តីសម្រេចរបស់តុលាការកំពូល ឯកសារលេខ* E138/1/7 *កថាខណ្ឌទី៣៧ ។*

*[៣] សេចក្តីសម្រេចរបស់តុលាការកំពូល ឯកសារលេខ* E138/1/7 *កថាខណ្ឌទី៣៥ ។*

ស្ថានភាពវេជ្ជសាស្ត្រពីរដែលមានអត្ថិភាពរួមគ្នានឹងធ្វើឲ្យលទ្ធភាពនៃការជាសះស្បើយរបស់គាត់មានការកើនឡើង ។ យើងខ្ញុំកត់សម្គាល់ឃើញថា មិនមានអ្នកជំនាញព្យាបាលតាមបែបធ្វើឲ្យសកម្មភាពពិសេសនោះទេនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែប្រសិនបើមានការវាយតម្លៃលើសកម្មភាពនៃការរស់នៅប្រចាំថ្ងៃរបស់គាត់អាចមានប្រយោជន៍ ហើយដំបូន្មានស្តីពីការកែសម្រួលណាមួយទៅលើបរិស្ថានរស់នៅរបស់គាត់គួរត្រូវស្វែងរក» ៗ[៤]

ចំពោះបញ្ហាការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យនៅក្រៅឃុំ អង្គជំនុំជម្រះនៃតុលាការកំពូលបានលើកឡើងថា «អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ខ្លួនមិនមានមូលដ្ឋានក្នុងការបន្តឃុំខ្លួនជនជាប់ចោទតទៅទៀត ដែលជាលទ្ធផលនៃការយល់ឃើញពីភាពមិនមានសម្បទា ការបំបែកបទចោទ និងការផ្អាកដំណើរការនីតិវិធី» ៗ[៥] អង្គជំនុំជម្រះតុលាការកំពូលផ្តល់ហេតុផលថា អង្គជំនុំជម្រះសាលាដំបូងអាចប្រើប្រាស់នូវរាល់វិធានការដែលមានដើម្បីអាចជួយដល់ជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យមានសម្បទាក្នុងការចូលរួមសវនាការ ។ ដូចនេះអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មូលដ្ឋានដែលមានពីមុនដែលអង្គជំនុំជម្រះសាលាដំបូងយកមកធ្វើជាសម្អាងហេតុក្នុងការបន្តឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នត្រូវមានសុពលភាពដដែល ពោលគឺដើម្បីធានាវត្តមានរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងអំឡុងពេលសវនាការ ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា អង្គជំនុំជម្រះសាលាដំបូង ដោយមានការពិភាក្សាជាមួយអ្នកវេជ្ជសាស្ត្រ និងផ្នែកវិលចរិកសមស្រប ត្រូវស្នើឲ្យមានការព្យាបាលបន្ថែមដល់ជនជាប់ចោទដែលអាចជួយឲ្យសុខភាពផ្នែកស្មារតីរបស់ជនជាប់ចោទបានប្រសើរឡើងដើម្បីឲ្យជនជាប់ចោទអាចមានស្មារតីចូលរួមសវនាការបាន ។ ការព្យាបាលនេះត្រូវតែធ្វើឡើងក្នុងមន្ទីរពេទ្យ ឬកន្លែងដទៃទៀតដែលសមស្របនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ជនជាប់ចោទត្រូវទទួលការពិនិត្យពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ផ្នែកវិកលចរិក និង/ឬផ្នែកចិត្តសាស្ត្រ មិនឲ្យលើសពីរយៈពេល៦ខែ ចាប់ពីពេលចាប់ផ្តើមព្យាបាលមក ។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការដោយមិនមានការពន្យាពេល ។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការឃុំខ្លួនជនជាប់ចោទត្រូវអនុវត្តនៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រហូតដល់ពេលការរៀបចំចាត់ចែងចាំបាច់នានា សម្រាប់ការព្យាបាលបន្ថែមនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្របដទៃទៀតត្រូវបានបំពេញរួចរាល់ ៗ[៦]

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ ម៉ាន់ថាន់ ពៅដារ៉ា**



អៀង ធីរិទ្ធ (រូបថត ៖ អ.វ.ត.ក)

[៤] សេចក្តីសម្រេចរបស់តុលាការកំពូល ឯកសារលេខ E138/1/7 កថាខណ្ឌទី៣៦ ។

[៥] សេចក្តីសម្រេចរបស់តុលាការកំពូល ឯកសារលេខ E138/1/7 កថាខណ្ឌទី៤០ ។

[៦] សេចក្តីសម្រេចរបស់តុលាការកំពូល ឯកសារលេខ E138/1/7 ផ្នែកសម្រេចសេចក្តី ។

មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : *dccam@online.com.kh*

គេហទំព័រ : *www.dccam.org* ឬ *www.cambodiatribunal.org*



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។




***ឆាយ ឈុនលី***

**ឈុនលី** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។



***ខី សុជាតា***

**សុជាតា** ជានិស្សិតថ្នាក់ បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។



***លីម ជ័យទត្ត***

**ជ័យទត្ត** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។ ជ័យទត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



***ចាន ប្រាថ្នា***

**ប្រាថ្នា** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវី នៅកម្ពុជា ។



ខៀវ សំផន ក្នុងបន្ទប់សវនាការ ខែធ្នូ ឆ្នាំ២០១១ (រូបថត ៖ អ.វ.ត.ក)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែធ្នូ ឆ្នាំ២០១១